Khmer/ខ្មែរ

Australian Government

ការបោះឆ្នោតគឺជាកាតព្វកិច្ច

# កូនសៀវភៅប្រជាមតិ

## ផ្លូវការរបស់អ្នក

កូនសៀវភៅនេះរួមមាន៖




ទំព័រ 5




ទំព័រ 23

# អំពីកូនសៀវភៅនេះ

កូនសៀវភៅប្រជាមតិផ្លូវការនេះមានឯកសារសំខាន់ៗពីរ៖
ខិត្តប័ណ្ណប្រជាមតិ Yes/No ផ្លូវការរបស់អ្នក និង
សៀវភៅមគ្គុទ្ទេសក៍ផ្លូវការរបស់អ្នកទៅកាន់ការធ្វើប្រជាមតិ ឆ្នាំ2023។




## ទំព័រ 5 ខិត្តប័ណ្ណប្រជាមតិ Yes/No ផ្លូវការរបស់អ្នក

### ទំព័រ 6 អ្វីដែលអាចកែប្រែនៅក្នុងរដ្ឋធម្មនុញ្ញ

ទំព័រនេះកំណត់ការកែប្រែដែលបានស្នើឡើង ដែលត្រូវធ្វើចំពោះរដ្ឋធម្មនុញ្ញ។

ច្បាប់ដែលបានស្នើឡើងត្រូវបានអនុម័តដោយសភាទាំងពីរ៖ ការកែប្រែរដ្ឋធម្មនុញ្ញ (សំឡេងជនជាតិដើម Aboriginal និងអ្នកកោះ Torres Strait) ឆ្នាំ 2023។

### ទំព័រ 7 ករណី Yes និង No

ករណីសម្រាប់ការបោះឆ្នោត Yes និងករណីសម្រាប់ការបោះឆ្នោត No ត្រូវបានបង្ហាញនៅក្បែរគ្នា។

ករណី Yes/No ត្រូវបានផ្តល់ដោយសមាជិកភាគច្រើននៃសភា ដែលបានបោះឆ្នោតគាំទ្រ ឬប្រឆាំងនឹងច្បាប់ដែលបានស្នើឡើង និងអ្នកដែលប្រាថ្នាចង់បន្តជំរុញករណីបែបនេះ។

**AEC មិនមានសិទ្ធិអំណាចនីតិបញ្ញត្តិដើម្បីកែប្រែ ឬពិនិត្យផ្ទៀងផ្ទាត់ករណី Yes ឬ No នោះទេ។**




## ទំព័រ 23 សៀវភៅមគ្គុទ្ទេសក៍ផ្លូវការរបស់អ្នកទៅកាន់ការធ្វើប្រជាមតិ ឆ្នាំ 2023

សៀវភៅមគ្គុទ្ទេសក៍ផ្លូវការមានព័ត៌មានសំខាន់អំពីការបោះឆ្នោត និងកន្លែងបោះឆ្នោតនានា និងសារពីស្នងការរៀបចំការបោះឆ្នោត។

សៀវភៅមគ្គុទ្ទេសក៍ផ្លូវការត្រូវបានរៀបចំឡើងដោយគណៈកម្មការរៀបចំការបោះឆ្នោតអូស្ត្រាលី (AEC)។



# កំណែដែលបានបកប្រែ និងទម្រង់ដែលអាចចូលប្រើប្រាស់បាន

**កូនសៀវភៅប្រជាមតិផ្លូវការរបស់អ្នកមានជាភាសាអង់គ្លេស និងភាសាដែលចម្រុះទៅដោយវប្បធម៌ និងភាសាផ្សេងៗគ្នា ភាសាប្រជាជាតិដំបូង (ជាសំឡេងតែប៉ុណ្ណោះ) ហើយមានទម្រង់ជាភាសាអង់គ្លេសសម្រាប់អ្នកបោះឆ្នោតដែលពិការភ្នែក ឬមានចក្ខុវិស័យកម្រិតទាប និងជាភាសាងាយស្រួលអាន (សៀវភៅមគ្គុទ្ទេសក៍ផ្លូវការតែប៉ុណ្ណោះ)។**

**សម្រាប់ព័ត៌មានបន្ថែមស្តីពីការបោះឆ្នោត និងការធ្វើប្រជាមតិ សូមហៅទូរសព្ទលេខ 1300 720 134 សម្រាប់ជំនួយជាភាសារបស់អ្នក។**

ទំព័រនេះត្រូវបានទុកឱ្យនៅទទេដោយចេតនា



Australian Government

ការបោះឆ្នោតគឺជាកាតព្វកិច្ច

ខិត្តប័ណ្ណប្រជាមតិ

# YES | NO

## ផ្លូវការរបស់អ្នក

# អ្វីដែលអាចកែប្រែនៅក្នុងរដ្ឋធម្មនុញ្ញ

## សេចក្តីថ្លែងការណ៍ផ្លូវការអំពីការកែប្រែដែលបានស្នើឡើងចំពោះរដ្ឋធម្មនុញ្ញ

ច្បាប់ដែលបានស្នើឡើង គឺការកែប្រែរដ្ឋធម្មនុញ្ញ (សំឡេងជនជាតិដើម Aboriginal និងអ្នកកោះ Torres Strait) ឆ្នាំ2023 (Constitution Alteration (Aboriginal and Torres Strait Islander Voice) 2023)) នឹងកែប្រែរដ្ឋធម្មនុញ្ញ ដោយការដាក់បញ្ចូលអត្ថបទដូចតទៅ បន្ទាប់ពីជំពូក VIII៖

### ជំពូក IX —ការទទួលស្គាល់ជនជាតិដើម Aboriginal និងអ្នកកោះ Torres Strait (Chapter IX—Recognition of Aboriginal and Torres Strait Islander Peoples)

#### 129 សំឡេងជនជាតិដើម Aboriginal និងអ្នកកោះ Torres Strait (Aboriginal and Torres Strait Islander Voice)

ក្នុងការទទួលស្គាល់ជនជាតិដើម Aboriginal និងអ្នកកោះTorres Strait ជាជនជាតិដើមដំបូងរបស់អូស្ត្រាលី៖

(i) នឹងមានស្ថាប័នមួយដែលហៅថា សំឡេងជនជាតិដើម Aboriginal និងអ្នកកោះ Torres Strait។

(ii) សំឡេងជនជាតិដើម Aboriginal និងអ្នកកោះ Torres Strait អាចធ្វើតំណាងទៅសភា និងរដ្ឋាភិបាលប្រតិបត្តិខុម្មុនវែល (Commonwealth) លើបញ្ហានានាទាក់ទងនឹងជនជាតិដើម Aboriginal និងអ្នកកោះ Torres Strait។

(iii) ស្ថិតនៅក្រោមរដ្ឋធម្មនុញ្ញនេះ សភាត្រូវមានអំណាចបង្កើតច្បាប់ទាក់ទិននឹងបញ្ហានានាទាក់ទងនឹងសំឡេងជនជាតិដើម Aboriginal និងអ្នកកោះ Torres Strait រួមទាំងសមាសភាព មុខងារ អំណាច និងនីតិវិធី។

ច្បាប់ដែលបានស្នើឡើងក៏នឹងកែប្រែរដ្ឋធម្មនុញ្ញ ដោយការដាក់បញ្ចូលអត្ថបទដូចតទៅ ទៅក្នុងតារាងមាតិកាក្នុងរដ្ឋធម្មនុញ្ញ បន្ទាប់ពីសេចក្តីយោងទៅ 'ជំពូក VIII ការកែប្រែរដ្ឋធម្មនុញ្ញ' ('Chapter VIII Alteration of the Constitution')៖

| | |
|---|---|
| ជំពូក IX | ការទទួលស្គាល់ជនជាតិដើម Aboriginal និងអ្នកកោះ Torres Strait |
| (Chapter IX | Recognition of Aboriginal and Torres Strait Islander Peoples) |



# នៅលើទំព័របន្ទាប់ អ្នកនឹងឃើញមានករណី **Yes** និង **No**

ការទាញហេតុផលសម្រាប់ករណីនីមួយៗត្រូវបានផ្តល់ដោយសមាជិកសភា និងសមាជិកព្រឹទ្ធសភាសហព័ន្ធភាគច្រើន ដែលបានបោះឆ្នោតគាំទ្រ ឬប្រឆាំងនឹងច្បាប់ដែលបានស្នើឡើងដើម្បីកែប្រែរដ្ឋធម្មនុញ្ញ និងអ្នកដែលប្រាថ្នាចង់បន្តជំរុញហេតុផលបែបនេះ។

អស់អ្នកដែលបានបោះឆ្នោតគាំទ្រច្បាប់ដែលបានស្នើ និងអ្នកដែលប្រាថ្នាចង់បន្តជំរុញហេតុផលបែបនេះ បានបង្កើតករណី Yes ខណៈពេលអ្នកដែលបានបោះឆ្នោតប្រឆាំងនឹងច្បាប់ដែលបានស្នើឡើង និងអ្នកដែលប្រាថ្នាចង់បន្តជំរុញហេតុផលបែបនេះ បានបង្កើតករណី No។

ចំនួនពាក្យត្រូវបានកំណត់ត្រឹម 2,000ពាក្យ ជាភាសាអង់គ្លេសសម្រាប់ករណីនីមួយៗ តាមផ្នែកទី 11(1) នៃ*ច្បាប់ប្រជាមតិ (ខដែលមានចែងស្តីពីយន្តការ/ដំណើរការ) ឆ្នាំ1984* (Cth)។

# ករណីសម្រាប់ការបោះឆ្នោត

# Yes

ករណីសម្រាប់ការបោះឆ្នោត **Yes** ចាប់ផ្តើមនៅ**ទំព័រ 10** ហើយបន្ទាប់មកត្រូវបានបង្ហាញនៅលើទំព័រជំនួសផ្សេងនានា។

**ច្បាប់ដែលបានស្នើឡើង៖**

ដើម្បីកែប្រែរដ្ឋធម្មនុញ្ញក្នុងការទទួលស្គាល់ ជនជាតិដើមដំបូងរបស់អូស្ត្រាលី ដោយការបង្កើតសំឡេងជនជាតិដើម Aboriginal និងអ្នកកោះ Torres Strait។

**A proposed law:**

To alter the Constitution to recognise the First Peoples of Australia by establishing an Aboriginal and Torres Strait Islander Voice.

**តើអ្នកណាជាអ្នកសរសេររឿងនេះ?**

ខ្លឹមសារនៃហេតុផលនេះ (ដែលអាចមើលបាននៅតាមគេហទំព័រ aec.gov.au/referendums/pamphlet.htm) ត្រូវបានអនុញ្ញាតដោយសមាជិកសភាភាគច្រើនដែលបានបោះឆ្នោតគាំទ្រច្បាប់ដែលបានស្នើឡើង ហើយប្រាថ្នាចង់បន្តជំរុញករណីបែបនេះ។ អត្ថបទនេះត្រូវបានបោះពុម្ពផ្សាយដោយគ្មានការកែប្រែដោយស្ថាប័នរៀបចំការបោះឆ្នោត។



# ករណីសម្រាប់ការបោះឆ្នោត

# No

ករណីសម្រាប់ការបោះឆ្នោត **No** ចាប់ផ្តើមនៅ**ទំព័រ 11** ហើយបន្ទាប់មកត្រូវបានបង្ហាញនៅលើទំព័រជំនួសផ្សេងនានា

**ច្បាប់ដែលបានស្នើឡើង៖**

ដើម្បីកែប្រែរដ្ឋធម្មនុញ្ញក្នុងការទទួលស្គាល់ ជនជាតិដើមដំបូងរបស់អូស្ត្រាលី ដោយការបង្កើតសំឡេងជនជាតិដើម Aboriginal និងអ្នកកោះ Torres Strait។

**A proposed law:**

To alter the Constitution to recognise the First Peoples of Australia by establishing an Aboriginal and Torres Strait Islander Voice.

**តើអ្នកណាជាអ្នកសរសេររឿងនេះ?**

ខ្លឹមសារនៃហេតុផលនេះ (ដែលអាចមើលបាននៅតាមគេហទំព័រ aec.gov.au/referendums/pamphlet.htm) ត្រូវបានអនុញ្ញាតដោយសមាជិកសភាភាគច្រើនដែលបានបោះឆ្នោតប្រឆាំងនឹងច្បាប់ដែលបានស្នើឡើង ហើយប្រាថ្នាចង់បន្តជំរុញករណីបែបនេះ។ អត្ថបទនេះត្រូវបានបោះពុម្ពផ្សាយដោយគ្មានការកែប្រែដោយស្ថាប័នរៀបចំការបោះឆ្នោត។

# ករណីសម្រាប់ការបោះឆ្នោត Yes

## បោះឆ្នោត Yes សម្រាប់អនាគតកាន់តែប្រសើរមួយសម្រាប់ជនជាតិដើម Aboriginal និងអ្នកកោះ Torres Strait ហើយនិងប្រជាជនអូស្ត្រាលីទាំងអស់។

## បោះឆ្នោត Yes ដើម្បីឯកភាព ក្តីសង្ឃឹម និងដើម្បីឱ្យមានភាពខុសគ្នាវិជ្ជមាន។

## ការបោះឆ្នោត YES គឺអំពី៖

**ការទទួលស្គាល់**

- **ការទទួលស្គាល់**ជនជាតិដើម Aboriginal និងអ្នកកោះ Torres Strait នៅក្នុងរដ្ឋធម្មនុញ្ញរបស់យើង និងការគោរពចំពោះវប្បធម៌ ហើយនិងប្រពៃណីដែលមានអាយុ65,000ឆ្នាំ។

**ការស្តាប់**

- **ការស្តាប់**ដំបូន្មានជនជាតិដើម Aboriginal និងអ្នកកោះ Torres Strait អំពីបញ្ហានានាដែលប៉ះពាល់ដល់ជីវិតរបស់ពួកគេ ដើម្បីឱ្យរដ្ឋាភិបាលធ្វើការសម្រេចចិត្តកាន់តែប្រសើរ។

**លទ្ធផលកាន់តែប្រសើរ**

- **ធ្វើឱ្យមានវឌ្ឍនភាពជាក់ស្តែង**ក្នុងវិស័យសុខាភិបាល ការអប់រំ ការងារ និងលំនៅដ្ឋានរបស់ជនជាតិដើមភាគតិច ដើម្បីឱ្យប្រជាជនមានជីវភាពកាន់តែប្រសើរ។

## វាគឺជាការផ្លាស់ប្តូរមួយ ដែលមានតែអ្នកប៉ុណ្ណោះអាចធ្វើឱ្យកើតឡើងបាន។

បោះឆ្នោត Yes ចំពោះគំនិតមួយដែលធ្វើចេញផ្ទាល់ពីជនជាតិដើម Aboriginal និងអ្នកកោះ Torres Strait៖ **ការទទួលស្គាល់រដ្ឋធម្មនុញ្ញតាមរយៈសំឡេង (Constitutional Recognition through a Voice)។**

### តើសំឡេងគឺជាអ្វី៖

សំឡេង (Voice) នឹងក្លាយជាគណៈកម្មការជនជាតិដើម Aboriginal និងអ្នកកោះ Torres Strait មួយ ដែលនឹងផ្តល់ដំបូន្មានដល់សភា និងរដ្ឋាភិបាលលើបញ្ហានានាដែលប៉ះពាល់ដល់សហគមន៍របស់ពួកគេ។

គណៈកម្មការនេះនឹងរួមបញ្ចូលជនជាតិដើមភាគតិច អូស្ត្រាលីមកពីគ្រប់រដ្ឋ និងដែនដី, កោះ Torres Strait និងអ្នកតំណាងនានាមកពីតំបន់ និងសហគមន៍ដាច់ស្រយាល។

សមាជិកនៃសំឡេងនឹងត្រូវបានជ្រើសរើសដោយជនជាតិដើម Aboriginal និងអ្នកកោះ Torres Strait នៅក្នុងតំបន់មូលដ្ឋានរបស់ពួកគេ ហើយបម្រើសម្រាប់រយៈពេលកំណត់មួយ។

## មូលហេតុដែលយើងត្រូវការវា៖

មានបញ្ហាប្រឈមធំៗដែលកំពុងប្រឈមមុខនឹងជនជាតិដើម Aboriginal និងអ្នកកោះ Torres Strait៖

- អាយុសង្ឃឹមរស់ជាមធ្យមគឺ៨ឆ្នាំ ខ្លីជាងជនជាតិអូស្ត្រាលីដែលមិនមែនជាជនជាតិដើមភាគតិច។
- អត្រាកាន់តែអាក្រក់នៃជំងឺ និងការស្លាប់របស់ទារក។
- អត្រាធ្វើអត្តឃាតខ្ពស់ជាងពីរដង។
- ឱកាសតិចតួចសម្រាប់ការអប់រំ និងបណ្តុះបណ្តាល។

គឺវាច្បាស់ណាស់ វិធីសាស្ត្របច្ចុប្បន្នមិនដំណើរការទេ។

ដើម្បីបិទគម្លាតទាំងនេះ ស្វែងរកដំណោះស្រាយ និងរៀបចំផែនការសម្រាប់ពេលអនាគត យើងត្រូវស្តាប់ដំបូន្មានពីជនជាតិដើម Aboriginal និងអ្នកកោះ Torres Strait អំពីបញ្ហានានាដែលប៉ះពាល់ដល់ជីវិត និងសហគមន៍របស់ពួកគេ។

## របៀបដែលសំឡេងនឹងដំណើរការ៖

**សំឡេងគឺអំពីដំបូន្មាន។**

នៅពេលដែលរដ្ឋាភិបាលស្តាប់ប្រជាជន អំពីបញ្ហានានាដែលប៉ះពាល់ដល់ពួកគេ ពួកគេ៖

- ធ្វើការសម្រេចចិត្តកាន់តែប្រសើរ។
- ទទួលបានលទ្ធផលកាន់តែប្រសើរ។

**ករណី Yes បន្ត** ទំព័រ12

**តើអ្នកណាជាអ្នកសរសេររឿងនេះ?**

**ខ្លឹមសារនៃហេតុផលនេះ (ដែលអាចមើលបាននៅតាមគេហទំព័រ aec.gov.au/referendums/pamphlet.htm) ត្រូវបានអនុញ្ញាតដោយសមាជិកសភាភាគច្រើនដែលបានបោះឆ្នោតគាំទ្រច្បាប់ដែលបានស្នើឡើង ហើយប្រាថ្នាចង់បន្តជំរុញករណីបែបនេះ។ អត្ថបទនេះត្រូវបានបោះពុម្ពផ្សាយដោយគ្មានការកែប្រែដោយស្នងការរៀបចំការបោះឆ្នោត។**



# ករណីសម្រាប់ការបោះឆ្នោត No

## ហេតុផលនានាដើម្បីបោះឆ្នោត NO – សេចក្តីសង្ខេប

ការធ្វើប្រជាមតិនេះមិនមែនគ្រាន់តែនិយាយអំពី “ការទទួលស្គាល់” នោះទេ។ សំណើឱ្យមានសំឡេង (Voice) មានកម្រិតធំធេងជាងនេះឆ្ងាយណាស់។

ប្រសិនបើត្រូវបានអនុម័ត វានឹងតំណាងការកែប្រែដ៏ធំបំផុតចំពោះរដ្ឋធម្មនុញ្ញរបស់យើង នៅក្នុងប្រវត្តិសាស្ត្ររបស់យើង។

វាមានហានិភ័យស្របច្បាប់ ជាមួយនឹងផលវិបាកនានាដែល គ្មានអ្នកណាដឹង។ វានឹងមានភាពបែកបាក់គ្នា និងមានលក្ខណៈអចិន្ត្រៃយ៍។

**ប្រសិនបើអ្នកមិនដឹងទេ សូមបោះឆ្នោត no។**

### ហានិភ័យ

យើងទាំងអស់គ្នាចង់ជួយជនជាតិដើមភាគតិចអូស្ត្រាលី នៅក្នុងសហគមន៍ដែលមានគុណវិបត្តិ។ ទោះយ៉ាងណាក៏ដោយ សំឡេងនេះមិនមែនជាចម្លើយ និងបង្ហាញពីហានិភ័យពិតប្រាកដចំពោះប្រព័ន្ធរដ្ឋាភិបាលរបស់នោះយើង។

សំឡេងនេះគ្របដណ្តប់ជាពិសេសគ្រប់ផ្នែកទាំងអស់នៃ “រដ្ឋាភិបាលប្រតិបត្តិ”។ នេះមានន័យថា គ្មានបញ្ហាណាមួយដែលហួសពីលទ្ធភាពរបស់សំឡេងនោះទេ។

ទីបំផុត តុលាការជាន់ខ្ពស់នឹងកំណត់អំណាចរបស់ខ្លួន មិនមែនសភាទេ។

វាប្រថុយនឹងបញ្ហាប្រឈមផ្លូវច្បាប់ ការពន្យារពេល និងរដ្ឋាភិបាលដែលដំណើរការច្របូកច្របល់។

### គ្មានអ្នកណាដឹង

មិនមានព័ត៌មានលម្អិតត្រូវបានផ្តល់ជូន អំពីរបៀបដែលសមាជិកនៃសំឡេងនឹងត្រូវបានជ្រើសរើស ឬរបៀបដែលវានឹងដំណើរការនោះទេ។ ប្រជាជនអូស្ត្រាលីកំពុងត្រូវបានស្នើឱ្យបោះឆ្នោតជាមុន មុនពេលដែលព័ត៌មានលម្អិតទាំងនេះត្រូវបានពិចារណា។

**ប្រជាជនអូស្ត្រាលីគួរតែមានព័ត៌មានលម្អិតមុនពេលបោះឆ្នោត មិនមែនក្រោយការបោះឆ្នោតនោះទេ។**

យើងមិនដឹងថាសម្លេងនឹងដំណើរការដោយរបៀបណាទេ យើងមិនដឹងថាអ្នកណាខ្លះនឹងនៅក្នុងសម្លេង ប៉ុន្តែយើងដឹងថាវានឹងបំបាក់បំបែកពួកយើងជាជនជាតិអូស្ត្រាលីជាអចិន្ត្រៃយ៍។

អ្នកគាំទ្រសម្លេងខ្លះនិយាយថា នេះគ្រាន់តែជាជំហានដំបូងសម្រាប់ការសុំទោស និងសំណង ហើយនិងការផ្លាស់ប្តូរយ៉ាងធំទូលាយផ្សេងទៀត។ ដូច្នេះ តើនឹងមានកើតឡើងបន្ទាប់ទៀត?

### ភាពបែកបាក់គ្នា

ការដាក់តម្កល់សំឡេងនៅក្នុងរដ្ឋធម្មនុញ្ញសម្រាប់តែជនជាតិអូស្ត្រាលីមួយក្រុម មានន័យថាការធ្វើឱ្យបែកបាក់ប្រទេសរបស់យើងជាអចិន្ត្រៃយ៍។

វាបង្កើតថ្នាក់ផ្សេងៗគ្នានៃភាពជាពលរដ្ឋតាមរយៈស្ថាប័នមួយដែលគ្មានអ្នកណាដឹង ដែលមានកម្លាំងពេញលេញរបស់រដ្ឋធម្មនុញ្ញនៅពីខាងក្រោយវា។ ជនជាតិដើមភាគតិចអូស្ត្រាលីជាច្រើនមិនគាំទ្ររឿងនេះទេ។

### អចិន្ត្រៃយ៍

ការដាក់សំឡេងក្នុងរដ្ឋធម្មនុញ្ញមានន័យថាវាទៅជាលក្ខណៈអចិន្ត្រៃយ៍។ យើងនឹងជាប់គាំងជាមួយនឹងផលវិបាកអវិជ្ជមាននានា។

## ហេតុផលដប់ដើម្បីបោះឆ្នោត NO

### 1. សំឡេងនេះគឺមានហានិភ័យស្របច្បាប់

រដ្ឋធម្មនុញ្ញរបស់ប្រទេសអូស្ត្រាលី គឺជាឯកសារច្បាប់ដ៏សំខាន់បំផុតរបស់យើង។ ពាក្យនីមួយៗអាចត្រូវបានបើកចំហសម្រាប់ការបកស្រាយ។

ប្រទេសអូស្ត្រាលីមិនបានកែប្រែរដ្ឋធម្មនុញ្ញរបស់ខ្លួនចាប់តាំងពីឆ្នាំ1977មកម្លេះ។ **នេះនឹងក្លាយជាការកែប្រែដ៏ធំបំផុតចំពោះលទ្ធិប្រជាធិបតេយ្យរបស់យើង នៅក្នុងប្រវត្តិសាស្ត្ររបស់ប្រទេសអូស្ត្រាលី។**

វាគឺជាការលោតចូលទៅក្នុងទឹងងឹតដែលគ្មានអ្នកណាដឹង។ សំឡេងនេះមិនទាន់បានគេសាកល្បងនៅឡើយទេ។ គ្មានស្ថាប័នធម្មនុញ្ញណាមួយដែលអាចប្រៀបផ្ទឹមដូចនេះទេ នៅគ្រប់ទីកន្លែងក្នុងពិភពលោក។

ការដាក់តម្កល់សំឡេងនៅក្នុងរដ្ឋធម្មនុញ្ញមានន័យថា វាបើកចំហចំពោះការប្រឈមផ្លូវច្បាប់ និងការបកស្រាយដោយតុលាការជាន់ខ្ពស់។

អ្នកជំនាញច្បាប់នានាមិនយល់ស្រប ហើយមិនអាចដឹងច្បាស់ថា តើតុលាការជាន់ខ្ពស់នឹងបកស្រាយការកែប្រែរដ្ឋធម្មនុញ្ញបែបណានោះទេ។

**ករណី No បន្ត** ទំព័រ13

**តើអ្នកណាជាអ្នកសរសេររឿងនេះ?**

**ខ្លឹមសារនៃហេតុផលនេះ (ដែលអាចមើលបាននៅតាមគេហទំព័រ aec.gov.au/referendums/pamphlet.htm) ត្រូវបានអនុញ្ញាតដោយសមាជិកសភាភាគច្រើនដែលបានបោះឆ្នោតប្រឆាំងនឹងច្បាប់ដែលបានស្នើឡើង ហើយប្រាថ្នាចង់បន្តជំរុញករណីបែបនេះ។ អត្ថបទនេះត្រូវបានបោះពុម្ពផ្សាយដោយគ្មានការកែប្រែដោយស្នងការរៀបចំការបោះឆ្នោត។**

- ប្រគល់នូវគុណតម្លៃសមនឹងទឹកប្រាក់កាន់តែប្រសើរ។

សំឡេងនឹងផ្តល់ដំបូន្មានលើបញ្ហាសំខាន់ៗដែលកំពុងប្រឈមមុខនឹងជនជាតិដើម Aboriginal និងអ្នកកោះ Torres Strait ចាប់ពីសេវាកម្មសុខភាពទារកកាន់តែប្រសើរ ដល់ការកែលម្អសេវាកម្មនានានៅតំបន់ដាច់ស្រយាល។

សភា និងរដ្ឋាភិបាលនឹងនៅតែទទួលខុសត្រូវចំពោះច្បាប់ កម្មវិធី និងការផ្តត់ផ្គង់ថវិកាទាំងអស់។

**លោក Patrick Dodson សមាជិកព្រឹទ្ធសភា រដ្ឋអូស្ត្រាលីខាងលិច អ្នកចាស់ទុំ Yawuru៖**
*"នៅពេលដែលសាធារណជនទូទៅត្រូវបានគេស្តាប់ និងចូលរួម ច្បាប់ និងគោលនយោបាយត្រូវបានបង្កើតកាន់តែប្រសើរ។ ដំបូន្មានពីសំឡេង នឹងធ្វើឱ្យការសម្រេចចិត្ត និងទិសដៅនានារបស់យើងកាន់តែបានជ្រាបព័ត៌មានច្បាស់លាស់ និងជោគជ័យកាន់តែច្រើន។ ការទទួលស្គាល់នៅក្នុងរដ្ឋធម្មនុញ្ញនឹងជួយព្យាបាលប្រទេសជាតិរបស់យើង។"*

## សំឡេង៖ ការពិតសំខាន់ៗ

- គំនិតកើតចេញពីជនជាតិដើម Aboriginal និងអ្នកកោះ Torres Strait។
- ទទួលស្គាល់ជនជាតិដើមដំបូង (First Peoples) នៅក្នុងរដ្ឋធម្មនុញ្ញរបស់យើង។
- គណកម្មការនៃជនជាតិដើម Aboriginal និងអ្នកកោះ Torres Strait។
- ផ្តល់ឱកាសដល់មនុស្សដើម្បីបញ្ចេញមតិ លើបញ្ហានានាដែលប៉ះពាល់ដល់ពួកគេ។
- ការស្តាប់នឹងមានន័យថាទទួលបានលទ្ធផលកាន់តែប្រសើរ – ហើយមានគុណតម្លៃសមនឹងទឹកប្រាក់។
- តំណាងនានាមកពីរដ្ឋ និងដែនដីទាំងអស់ សហគមន៍អ្នកកោះ Torres Strait និងសហគមន៍ដាច់ស្រយាលនានា។
- នឹងរួមបញ្ចូលយុវជន និងសមតុល្យបុរស និងស្ត្រី។
- សភា និងរដ្ឋាភិបាលនឹងនៅតែទទួលខុសត្រូវចំពោះច្បាប់ កម្មវិធី និងការផ្តត់ផ្គង់ថវិកាទាំងអស់។

## សូមបន្តអានសម្រាប់ហេតុផល 8 បន្ថែមទៀតដើម្បីបោះឆ្នោត YES។

# 1. គំនិតនេះធ្វើចេញផ្ទាល់ពីជនជាតិដើម Aboriginal និងអ្នកកោះ Torres Strait។

ការបោះឆ្នោត Yes មានន័យថា៖

- ការគាំទ្រសេចក្តីប្រាថ្នាដែលដាក់ចេញដោយជនជាតិដើម Aboriginal និងអ្នក Torres Strait អស់ជាច្រើនទសវត្សរ៍។
- ការទទួលយកសំណើដែលគាំទ្រជាង 80% ដោយជនជាតិដើម Aboriginal និងអ្នកកោះ Torres Strait។

**ការអំពាវនាវរកសំឡេងមិនបានធ្វើចេញពីអ្នកនយោបាយទេ។**

ក្នុងឆ្នាំ 2017 បន្ទាប់ពីការងារជាច្រើនឆ្នាំ និងការសន្ទនារាប់មិនអស់នៅគ្រប់ផ្នែកនៃប្រទេស មេដឹកនាំ និងអ្នកចាស់ទុំជនជាតិដើម Aboriginal និងអ្នកកោះ Torres Strait ជិត 250 *នាក់បានគាំទ្រសេចក្តីថ្លែងការណ៍ Uluru ចេញពីបេះដូង (Uluru Statement from the Heart)*។

ការអំពាវនាវឱ្យមានការទទួលស្គាល់ក្នុងរដ្ឋធម្មនុញ្ញ តាមរយៈសំឡេង។

ការស្នើសុំឱ្យយើងជួយធ្វើការផ្លាស់ប្តូរជាក់ស្តែងនៅក្នុងជីវិតរបស់ពួកគេ និងបង្កើតឱកាសកាន់តែប្រសើរសម្រាប់កូនៗរបស់ពួកគេ។

> ប្រជាជនអូស្ត្រាលីមកពីគ្រប់មជ្ឈដ្ឋាន គ្រប់ជំនឿ និងវប្បធម៌ ហើយគ្រប់ភាគីនយោបាយបានផ្តល់ការគាំទ្ររបស់ពួកគេចំពោះសំណើនេះ។

ឥឡូវនេះ យើងអាចធ្វើឱ្យវាក្លាយជាការពិត។

ការបោះឆ្នោត Yes គឺជាទង្វើនៃការរួបរួមគ្នាដែលនឹងនាំឱ្យប្រជាជនអូស្ត្រាលីមានភាពរួបរួមសាមគ្គីគ្នា។

# 2. ការទទួលស្គាល់រដ្ឋធម្មនុញ្ញសម្រាប់លទ្ធផលច្បាស់លាស់។

ការទទួលស្គាល់រដ្ឋធម្មនុ ញ្ញគឺជាសេចក្តីថ្លែងការណ៍ដ៏មានឥទ្ធិពលមួយ ដែលនឹងជំរុញឱ្យមានការកែប្រែជាក់ស្តែង។

**ការបោះឆ្នោត Yes មានន័យថា៖**

- ការទទួលស្គាល់ជនជាតិដើម Aboriginal និងអ្នកកោះ Torres Strait ថាជាជនជាតិដើមដំបូងរបស់អូស្ត្រាលី។
- ការអបអរសាទរ និងចែករំលែកប្រវត្តិសាស្ត្រដែលមានអាយុ 65,000 ឆ្នាំ។
- ការផ្ញើសារដ៏មានអានុភាពមួយ ទៅកាន់ពិភពលោកអំពីឯកភាពរបស់ប្រទេសអូស្ត្រាលី។

ករណី Yes បន្ត ទំព័រ 14

**តើអ្នកណាជាអ្នកសរសេររឿងនេះ?** **ខ្លឹមសារនៃហេតុផលនេះ (ដែលអាចមើលបាននៅតាមគេហទំព័រ aec.gov.au/referendums/pamphlet.htm) ត្រូវបានអនុញ្ញាតដោយសមាជិកសភាភាគច្រើនដែលបានបោះឆ្នោតគាំទ្រច្បាប់ដែលបានស្នើឡើង ហើយប្រាថ្នាចង់បន្តជំរុញករណីបែបនេះ។ អត្ថបទនេះត្រូវបានបោះពុម្ពផ្សាយដោយគ្មានការកែប្រែដោយស្ថានការរៀបចំការបោះឆ្នោត។**





**"ខ្ញុំនឹងប្រមើលទុកជាមុនមួយទសវត្សរ៍ ឬច្រើនជាងនេះថានឹងមានបណ្តឹងវិវាទរដ្ឋធម្មនុញ្ញ និងច្បាប់រដ្ឋបាលដែលកើតចេញពីសំឡេង..."**
(*Ian Callinan AC KC អតីតចៅក្រមតុលាការជាន់ខ្ពស់*)[1]

នេះនឹងបើកច្រកការកើតមានបញ្ហាស្របច្បាប់ជាច្រើន។

## 2. មិនមានព័ត៌មានលម្អិត

នេះគឺជាការសម្រេចចិត្តដ៏ធំមួយ។ ទោះជាយ៉ាងណាក្តី **រដ្ឋាភិបាលនឹងមិនបង្ហាញព័ត៌មានលម្អិតសំខាន់ៗ មុនការបោះឆ្នោតឡើយ**។

យើងមិនដឹងថាវានឹងជួយសហគមន៍ដែលមានគុណវិបត្តិ និងបិទគម្លាតនេះយ៉ាងដូចម្តេចនោះទេ។

យើងមិនដឹងថាសម្លេងនេះនឹងមានសមាជិកប៉ុន្មាននាក់នោះទេ។

យើងមិនដឹងថាតើពួកគេនឹងត្រូវបានគេជ្រើសតាំង ឬជ្រើសរើសឬការនេះនឹងកើតឡើងដោយរបៀបណានោះទេ។

យើងមិនដឹងថាតើវានឹងធ្វើការតំណាង ឬត្រូវទទួលខុសត្រូវដោយរបៀបណានោះទេ។

> ព័ត៌មានលម្អិតទាំងនេះនឹងត្រូវបានពិចារណា បន្ទាប់ពីប្រជាជនអូស្ត្រាលីបានបោះឆ្នោតរួចហើយ

យោងតាមយុទ្ធនាការ Yes វា *"មិនសមហេតុផល"* ក្នុងការមានព័ត៌មានលម្អិតមុនពេលបោះឆ្នោត៖

"វាមិនសមហេតុផលទេក្នុងការធ្វើការពិគ្រោះយោបល់ព័ត៌មានលម្អិតលម្អិតនោះ រហូតដល់យើងមានការគាំទ្រពីប្រជាជនអូស្ត្រាលីក្នុងការកែប្រែរដ្ឋធម្មនុញ្ញ។"
(*Yes23 ខិត្តប័ណ្ណ*)

នេះគឺជាដំណើរការខុសផ្លូវ។

អ្នកនឹងមិនទិញផ្ទះដោយមិនបានពិនិត្យមើលវា ឬក៏ទិញរថយន្តដោយមិនបានសាកល្បងការបើកបរវានោះទេ។

ប៉ុន្តែអ្នកកំពុងត្រូវបានស្នើសុំឱ្យបោះឆ្នោត ដើម្បីកែប្រែរដ្ឋធម្មនុញ្ញរបស់យើងដោយគ្មានព័ត៌មានលម្អិត។

ជនជាតិអូស្ត្រាលីមិនគួរត្រូវបានស្នើសុំឱ្យចុះហត្ថលេខាលើ មូលប្បទានប័ត្រចំហនោះទេ។

"តើជនជាតិអូស្ត្រាលីអាចយល់ព្រមចំពោះអ្វីមួយ ដែលយើងមិនដឹងព័ត៌មានលម្អិតយ៉ាងដូចម្តេច?"
*(សមាជិកព្រឹទ្ធសភា Kerrynne Liddle រដ្ឋមន្ត្រីស្រមោលសម្រាប់កិច្ចការពារកុមារ និងការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងស្ត្រី Arrernte)*

## 3. វាបំបែកបំបាក់ពួកយើង

> ការដាក់តម្កល់ស្ថាប័នមួយសម្រាប់ជនជាតិអូស្ត្រាលីតែមួយក្រុមនៅក្នុងរដ្ឋធម្មនុញ្ញរបស់យើងមានន័យថា ការធ្វើឱ្យបំបែកបែកបាក់ប្រទេសរបស់យើងជាអចិន្ត្រៃយ៍។ ជនជាតិដើមភាគតិចអូស្ត្រាលីជាច្រើនមិនយល់ស្របនឹងរឿងនេះទេ។

**"សំឡេងនេះនឹងមិនបង្រួបបង្រួមយើងទេ វានឹងបែងចែកយើងតាមពូជសាសន៍។"**
(*សមាជិកព្រឹទ្ធសភា Jacinta Nampijinpa Price រដ្ឋមន្ត្រីស្រមោលសម្រាប់ជនជាតិដើមអូស្ត្រាលី និងស្ត្រី Warlpiri*)

នេះផ្ទុយទៅនឹងគោលការណ៍សំខាន់មួយនៃប្រព័ន្ធប្រជាធិបតេយ្យរបស់យើង ដែលប្រជាជនអូស្ត្រាលីទាំងអស់មានភាពស្មើគ្នាចំពោះមុខច្បាប់។

"ការដាក់បញ្ចូលផ្នែក 129 ដែលបានស្នើឡើងនឹងមានន័យថា យើងក្លាយជាប្រជាជាតិមួយ ដែលនៅពេលណាយើង ឬបុព្វបុរសរបស់យើងបានមកប្រទេសនេះដំបូង យើងមិនស្មើគ្នាទាំងអស់នោះទេ។"
(*David Jackson AM KC អតីតចៅក្រមតុលាការសហព័ន្ធ*) [2]

រដ្ឋធម្មនុញ្ញរបស់យើងជាកម្មសិទ្ធិរបស់ប្រជាជនអូស្ត្រាលីទាំងអស់។ សភារបស់យើងនៅទីនោះ ដើម្បីតំណាងឱ្យប្រជាជនអូស្ត្រាលីទាំងអស់។ ឥឡូវនេះវារួមមានសមាជិក និងសមាជិកព្រឹទ្ធសភាជនជាតិដើមភាគតិចចំនួន 11 នាក់ ជាចំនួនច្រើនជាងពីមុនៗ។

ភ្លេងជាតិរបស់យើងត្រូវបានផ្លាស់ប្តូរនាពេលថ្មីៗនេះ ដើម្បីឆ្លុះបញ្ចាំងពីការពិតថាយើងជា "ប្រជាជនតែមួយ ហើយមានសេរីភាព។"

**ផ្ទុយទៅវិញ សំឡេងនេះនឹងបែងចែកជនជាតិអូស្ត្រាលីជាអចិន្ត្រៃយ៍ នៅក្នុងច្បាប់ និងស្មារតី។**

1 សារព័ត៌មាន The Australian, 17/12/2022
2 ការដាក់ស្នើការសាកសួររបស់សភា 11/04/2023

ករណី No បន្ត ទំព័រ 15

**តើអ្នកណាជាអ្នកសរសេររឿងនេះ?** **ខ្លឹមសារនៃហេតុផលនេះ (ដែលអាចមើលបាននៅតាមគេហទំព័រ aec.gov.au/referendums/pamphlet.htm) ត្រូវបានអនុញ្ញាតដោយសមាជិកសភាភាគច្រើនដែលបានបោះឆ្នោតប្រឆាំងនឹងច្បាប់ដែលបានស្នើឡើង ហើយប្រាថ្នាចង់បន្តជំរុញករណីបែបនេះ។ អត្ថបទនេះត្រូវបានបោះពុម្ពផ្សាយដោយគ្មានការកែប្រែដោយស្ថានការរៀបចំការបោះឆ្នោត។**

- ការបង្កើតភាពខុសគ្នាជាក់ស្តែងសម្រាប់អនាគត។

ជំនាន់នៃជនជាតិដើម Aboriginal និងអ្នកកោះ Torres Strait បានធ្វើឱ្យប្រទេសជាតិរបស់យើងកាន់តែល្អតលាស់ជាមួយនឹងវប្បធម៌ និងភាពច្នៃប្រឌិតរបស់ពួកគេ ចំណេះដឹងរបស់ពួកគេអំពីដី និងទឹក ហើយនិងការរួមចំណែករបស់ពួកគេចំពោះជីវិតអូស្ត្រាលី។

ទ្វីបសម័យបុព្វកាលរបស់យើង គឺជាជម្រកវប្បធម៌រស់រវើកដ៏ចំណាស់បំផុតរបស់ពិភពលោក។ ការទទួលស្គាល់រឿងនេះនៅក្នុងរដ្ឋធម្មនុញ្ញរបស់យើង គឺជាវិធីដ៏បំផុសគំនិតមួយដើម្បីអបអរប្រវត្តិសាស្ត្ររួមរបស់យើង។

ការបោះឆ្នោត Yes គឺជាទង្វើនៃការផ្សះផ្សាមួយ ដែលនឹងផ្តល់លទ្ធផលយ៉ាងពិតប្រាកដ។

> ទម្រង់នៃការទទួលស្គាល់ដែលជនជាតិដើមភាគតិចអូស្ត្រាលី កំពុងស្នើសុំឱ្យយើងគាំទ្រនោះគឺសំឡេង។ ជាមធ្យោបាយមួយសម្រាប់ការកែប្រែជាក់ស្តែង។

**Johnathan Thurston ជើងឯក និងគ្រូបង្វឹក NRL បុរស Gunggari៖**

*"យុវជនរបស់យើងសមនឹងទទួលបានឱកាសដើម្បី ប្រឹងប្រែងអស់ពីសមត្ថភាពរបស់ពួកគេ។ ខ្ញុំធ្វើការយ៉ាងជិតស្និទ្ធជាមួយសិស្សសាលានៅក្នុងសហគមន៍ Yarrabah ក្នុងរដ្ឋឃ្វីនស្លែន។ ខ្ញុំបានឃើញឧបសគ្គនានាដែលពួកគេប្រឈមមុខ។ គ្មានអ្នកណាយល់ដឹងច្បាស់ជាងសហគមន៍មូលដ្ឋានរបស់ពួកគេទេ។ ការផ្តល់ឱកាសឱ្យពួកគេបញ្ចេញមតិនឹងមានន័យថា កូនៗរបស់យើងកាន់តែឈានដល់សក្តានុពលរបស់ពួកគេ។ នោះគឺជាអ្វីដែលសំឡេងចង់បាន។"*

## 3. ធានាថាមនុស្សមានជីវិតរស់នៅកាន់តែប្រសើរ។

សំឡេងគឺ ជាមធ្យោបាយមួយដើម្បីផ្តល់នូវការកែលម្អពិតប្រាកដសម្រាប់ជនជាតិដើម Aboriginal និងអ្នកកោះ Torres Strait ក្នុង៖

- អាយុសង្ឃឹមរស់ជាមធ្យម។
- ការស្លាប់ និងសុខភាពរបស់ទារក។
- ការអប់រំ និងការងារ។

អស់រយៈពេលជាយូរមកហើយ រដ្ឋាភិបាលនានាដោយមានគោលបំណងល្អ បានចំណាយប្រាក់រាប់ពាន់លានដុល្លារដើម្បីព្យាយាមដោះស្រាយបញ្ហាទាំងនេះ។

ប៉ុន្តែពួកគេមិនបានសម្រេចនូវការកែលម្អយូរអង្វែងទេ ដោយសារពួកគេមិនបានស្តាប់សាធារណជនទូទៅ។

វិធីសាស្ត្របច្ចុប្បន្នត្រូវបានបាក់បែក ហើយសំឡេង គឺជាឱកាសដ៏ល្អបំផុតរបស់យើងក្នុងការជួសជុលវា។

គ្មាននរណាម្នាក់គិតថាសំឡេង នឹងដោះស្រាយអ្វីគ្រប់យ៉ាងភ្លាមៗនោះទេ - ប៉ុន្តែទីបំផុត យើងនឹងមានវិធីសាស្ត្រត្រឹមត្រូវដាក់នៅនឹងកន្លែង។

**នេះគឺជាឧទាហរណ៍បីដែលការស្តាប់ជនជាតិដើមភាគតិច បានផ្តល់លទ្ធផលកាន់តែប្រសើរ។**

**ចូរស្រមៃមើលវឌ្ឍនភាពដែលប្រទេសអូស្ត្រាលីអាចចម្រើនទៅមុខ ជាមួយនឹងសំឡេង។**

### ការស្តាប់បានសម្រេចផល៖ សេវាកម្មសុខភាពកាន់តែប្រសើរ

សេវាកម្មវេជ្ជសាស្ត្រជនជាតិដើម Aboriginal ដែលគ្រប់គ្រងដោយសហគមន៍ ផ្តល់ការងារដល់ជនជាតិដើមភាគតិចក្នុងមូលដ្ឋាន។

ពួកគេដំណើរការគ្លីនិក និងចុះទៅពិនិត្យតំបន់ដាច់ស្រយាល ដោយផ្តល់សេវាកម្មសំខាន់ៗ ដូចជាការចាក់ថ្នាំបង្ការដល់កុមារ។

នៅភាគអាគ្នេយ៍នៃរដ្ឋឃ្វីនស្លែន សេវាកម្មវេជ្ជសាស្ត្រជនជាតិដើម Aboriginal ក្នុងមូលដ្ឋាន និងសហគមន៍បានធ្វើការរួមគ្នា ដើម្បីបង្កើនចំនួននៃការពិនិត្យសុខភាពប្រចាំឆ្នាំដ៏ធំសម្បើមពី 550 ទៅ 20,000 ក្នុងរយៈពេល 10 ឆ្នាំ។

### ការស្តាប់បានសម្រេចផល៖ លទ្ធផលកាន់តែប្រសើរក្នុងការអប់រំ

គ្រួសារ និងអ្នកដឹកនាំសហគមន៍បានចូលរួមគ្រប់ជំហាននៃសាលារៀន Dhupuma Barker ថ្មីនៅ Arnhem Land ចាប់ពីការធ្វើផែនការមេរៀនរហូតដល់ឯកសណ្ឋាន និងអាហារថ្ងៃត្រង់។

ភាពជាដៃគូពិតប្រាកដបានជំរុញ**ឱ្យមានអត្រាចូលរៀននៅសាលាដ៏រឹងមាំ និងលទ្ធផលកាន់តែប្រសើរ**។ ក្រុមមនុស្សយន្ត 'Dhupuma Firebirds' ថ្មីៗនេះ បានប្រកួតប្រជែងក្នុងជើងឯកអន្តរជាតិ VEX ក្នុងរដ្ឋតិចសាស់ ជាក្រុមដំបូងគេមកពីដែនដីខាងជើងដែលមាន គុណសម្បត្តិគ្រប់គ្រាន់មិនដែលធ្លាប់មាន។

ករណី Yes បន្ត ទំព័រ 16

**តើអ្នកណាជាអ្នកសរសេររឿងនេះ?** **ខ្លឹមសារនៃហេតុផលនេះ (ដែលអាចមើលបាននៅតាមគេហទំព័រ aec.gov.au/referendums/pamphlet.htm) ត្រូវបានអនុញ្ញាតដោយសមាជិកសភាភាគច្រើនដែលបានបោះឆ្នោតគាំទ្រច្បាប់ដែលបានស្នើឡើង ហើយប្រាថ្នាចង់បន្តជំរុញករណីបែបនេះ។ អត្ថបទនេះត្រូវបានបោះពុម្ពផ្សាយដោយគ្មានការកែប្រែដោយស្នងការរៀបចំការបោះឆ្នោត។**





"យើងទាំងអស់គ្នាជាជនជាតិអូស្ត្រាលី។ ហើយនោះគឺជារបៀបដែលវាគួរតែបានបញ្ចប់ត្រឹមហ្នឹង។ វាមិនគួរត្រូវបានបែងចែកដោយអ្វីដែលហៅថាសំឡេងនោះទេ ដែលនឹងបំបែកប្រទេសនេះជាពីរចំពាក់កណ្តាល។"
(*Ian Conway, Central Arrernte អ្នកថែរក្សាជាន់ខ្ពស់*)

## 4. វានឹងមិនជួយជនជាតិដើមភាគតិចអូស្ត្រាលីទេ

យើងទាំងអស់គ្នាចង់ជួយជនជាតិដើមភាគតិចអូស្ត្រាលី នៅក្នុងសហគមន៍ដែលមានគុណវិបត្តិ ដើម្បីបិទគម្លាត និងសម្រេចបាននូវការផ្សះផ្សា។

**ទោះជាយ៉ាងណាក៏ដោយ ប្រព័ន្ធរដ្ឋបាលកាន់តែស្មុគស្មាញមិនមែនជាចម្លើយនោះទេ។**

បច្ចុប្បន្ន មានស្ថាប័នតំណាងជនជាតិដើមភាគតិចរាប់រយនាក់ នៅគ្រប់កម្រិតនៃរដ្ឋាភិបាល រួមជាមួយនឹងទីភ្នាក់ងារជនជាតិដើមភាគតិចអូស្ត្រាលីដែលមានបុគ្គលិកចំនួន 1,400 នាក់។

ការធ្វើមជ្ឈការសំឡេង មានហានិភ័យដែលមើលរំលងតម្រូវការរបស់សហគមន៍ក្នុងតំបន់ និងដាច់ស្រយាល។

"សំឡេងជាតិមិនអាចនិយាយជំនួសប្រទេសបានទេ។"
(*Nyunggai Warren Mundine AO ជនជាតិអូស្ត្រាលីសម្រាប់សមាជិកក្រុមប្រឹក្សាឯកភាព និងបុរស Bundjalung*)

នៅពេលនេះ សំឡេងជាច្រើនកំពុងស្រែករកជំនួយ ក្នុងការដោះស្រាយបញ្ហាសង្គម ដែលបំផ្លិចបំផ្លាញនៅក្នុងសហគមន៍ដាច់ស្រយាលមួយចំនួន។ អ្វីដែលត្រូវការនោះគឺសកម្មភាព។

**"អ្វីដែលយើងត្រូវការនៅទីក្រុង Canberra គឺត្រចៀក មិនមែនសំឡេងទេ។"**
(*សមាជិកព្រឹទ្ធសភា Jacinta Nampijinpa Price រដ្ឋមន្ត្រីស្រមោលសម្រាប់ជនជាតិដើមអូស្ត្រាលី និងស្ត្រី Warlpiri*)

## 5. គ្មានបញ្ហាណាដែលហួសពីវិសាលភាពរបស់វាទេ

គំរូសំឡេងនេះមិនមែនសម្រាប់តែសភាប៉ុណ្ណោះទេ មានកម្រិតធំធេងជាងនេះឆ្ងាយណាស់ - ទៅគ្រប់វិស័យនៃ "រដ្ឋាភិបាលប្រតិបត្តិ"។ **នោះរួមបញ្ចូលទាំងក្រសួងរដ្ឋាភិបាល ទីភ្នាក់ងារ និងស្ថាប័នផ្សេងទៀត (ដូចជាធនាគារជាតិ)។**

ការសម្រេចចិត្តទាក់ទងនឹងសេដ្ឋកិច្ច សន្តិសុខជាតិ ហេដ្ឋារចនាសម្ព័ន្ធ សុខភាព ការអប់រំ និងអ្វីៗជាច្រើនទៀត នឹងស្ថិតនៅក្នុងវិសាលភាពរបស់វា។

តាមសំដីរបស់សមាជិកក្រុមការងារប្រជាមតិរបស់រដ្ឋាភិបាល៖

"សំឡេងនឹងអាចនិយាយទៅកាន់គ្រប់ផ្នែកទាំងអស់នៃរដ្ឋាភិបាល រួមទាំងគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រី មន្ត្រីសាធារណៈ និងការិយាល័យ និងទីភ្នាក់ងារស្របច្បាប់ឯករាជ្យ ដូចជាធនាគារជាតិ... រដ្ឋាភិបាលមិនអាចបិទសំឡេងបានទេ។"
(*សាស្ត្រាចារ្យ Megan Davis និង Gabrielle Appleby*)[3]

តាមសម្តីរបស់សាស្ត្រាចារ្យច្បាប់ធម្មនុញ្ញដែលគាំទ្រសំឡេង៖

"ខ្ញុំគិតថាវាមានកំហុសដ៏ធ្ងន់ធ្ងរ ពីព្រោះអ្វីដែលវាធ្វើគឺរក្សានូវការត្រួតពិនិត្យពេញលេញនៃសកម្មភាពរបស់អាជ្ញាធររដ្ឋាភិបាល។ នេះមានន័យថាសំឡេងអាចធ្វើអត្ថាធិប្បាយលើអ្វីគ្រប់យ៉ាង ចាប់ពីនាវាមុជទឹករហូតដល់សំបុត្រចតរថយន្ត... យើងនឹងមានអន្តរាគមន៍តាមផ្លូវតុលាការជាប្រចាំ។"
(*សាស្ត្រាចារ្យ Greg Craven AO*)[4]

អ្នកជំនាញផ្នែកច្បាប់ជាច្រើនបានសម្តែងការព្រួយបារម្ភអំពីវិសាលភាពរបស់វា ទោះជាយ៉ាងណាក្តី កង្វល់របស់ពួកគេត្រូវបានគេមើលរំលង។

## 6. វាប្រថុយនឹងការពន្យារពេល និងដំណើរការច្របូកច្របល់

សភាអូស្ត្រាលីដោះស្រាយជាមួយផ្នែកច្បាប់រាប់រយក្នុងមួយឆ្នាំ។

វិសាលភាពរបស់សំឡេងនេះហួសពីសភា ដោយគ្របដណ្តប់ក្រសួង ទីភ្នាក់ងារ និងគ្រប់ផ្នែកទាំងអស់នៃ "រដ្ឋាភិបាលប្រតិបត្តិ"។

តើសំឡេងនឹងដោះស្រាយរឿងនេះដោយរបៀបណា?

**ប្រសិនបើសំឡេងមិនពេញចិត្តនឹងវិធីដែលខ្លួនបានពិគ្រោះយោបល់ ឬការសម្រេចមួយ វាអាចប្តឹងទៅតុលាការ។ តើនេះនឹងត្រូវចំណាយពេលអស់ប៉ុន្មាន?**

អ្នកជំនាញផ្នែកច្បាប់ជាច្រើនបានព្រមានថា នេះនឹងបណ្តាលឱ្យមានការពន្យារពេលយ៉ាងច្រើនក្នុងការធ្វើសេចក្តីសម្រេច។

---

3 សារព័ត៌មាន The Australian, 1/4/2023
4 សារព័ត៌មាន Daily Mail, 24/3/2023

ករណី No បន្ត ទំព័រ 17

**តើអ្នកណាជាអ្នកសរសេររឿងនេះ?** **ខ្លឹមសារនៃហេតុផលនេះ (ដែលអាចមើលបាននៅតាមគេហទំព័រ aec.gov.au/referendums/pamphlet.htm) ត្រូវបានអនុញ្ញាតដោយសមាជិកសភាភាគច្រើនដែលបានបោះឆ្នោតប្រឆាំងនឹងច្បាប់ដែលបានស្នើឡើង ហើយប្រាថ្នាចង់បន្តជំរុញករណីបែបនេះ។ អត្ថបទនេះត្រូវបានបោះពុម្ពផ្សាយដោយគ្មានការកែប្រែដោយស្នងការរៀបចំការបោះឆ្នោត។**

នាយកសាលា Phillip Heath មានប្រសាសន៍ថា៖
*"ការស្ដាប់សហគមន៍គឺជា ព្រឹត្តិការណ៍មួយដែលជះឥទ្ធិពលដល់ការផ្លាស់ប្ដូរដ៏សំខាន់នៅក្នុងការអប់រំក្នុងតំបន់ និងពីចម្ងាយ។"*

### ការស្ដាប់បានសម្រេចផល៖ អនុរក្សជនជាតិដើមភាគតិច

មានអនុរក្សជនជាតិដើមភាគតិច 2,000 នាក់ ដែលកំពុងធ្វើការនៅលើទឹកដីដែលពួកគេរស់នៅ។

អនុរក្សថែទាំបរិស្ថានរបស់យើង ដោយ**ធ្វើការដើម្បីការពារភ្លើងឆេះព្រៃ គ្រប់គ្រងសត្វព្រៃសាហាវ និងការកែលម្អសុខភាពនៃទន្លេរបស់យើង។**

ការស្ដាប់អនុរក្សជនជាតិដើមភាគតិច មានន័យថាការចែករំលែកចំណេះដឹង និងការភ្ជាប់ទំនាក់ទំនងជាមួយដី និងទឹករបស់យើងដែលមានអាយុ 65,000 ឆ្នាំ។

**បោះឆ្នោត Yes ដើម្បីទទួលបានលទ្ធផលកាន់តែប្រសើរ នៅជុំវិញប្រទេសអូស្ត្រាលី។**

**បោះឆ្នោត Yes ដើម្បីជួយបិទគម្លាត។**

## 4. នាំឱ្យប្រទេសរបស់យើងមានភាពរួបរួមសាមគ្គីគ្នា។

ការបោះឆ្នោត Yes មានន័យថា៖

- ធ្វើការផ្សះផ្សាជាមួយអតីតកាលរបស់យើង និងផ្លាស់ទីទៅអនាគតកាន់តែប្រសើរមួយ។
- ជាការផ្លាស់ប្ដូរមួយ ដែលមានតែអ្នកប៉ុណ្ណោះអាចធ្វើឱ្យកើតឡើងបាន។

អូស្ត្រាលីមានការវិវត្តន៍ច្រើន ចាប់តាំងពីរដ្ឋធម្មនុញ្ញរបស់យើងចូលជាធរមានក្នុងឆ្នាំ 1901។

ឥឡូវនេះ យើងអបអរសាទរជនជាតិដើមភាគតិចអូស្ត្រាលីយ៉ាងត្រឹមត្រូវ និងការរួមចំណែករបស់ពួកគេចំពោះប្រទេសរបស់យើង។

នៅក្នុងការធ្វើប្រជាមតិឆ្នាំ 1967 ប្រជាជនអូស្ត្រាលី 90% បានបោះឆ្នោត Yes ដើម្បីកែប្រែរដ្ឋធម្មនុញ្ញ ដូច្នេះជនជាតិដើម Aboriginal និងអ្នកកោះ Torres Strait នឹងត្រូវបានរាប់បញ្ចូលក្នុងចំនួនប្រជាជន តាមលំនាំដូចគ្នានឹងមនុស្សគ្រប់រូបដែរ។

វាជាជំហានរួបរួមមួយទៅអនាគត។

រួមគ្នា យើងមានឱកាសដើម្បីបោះជំហានបន្ទាប់ - ការទទួលស្គាល់ជនជាតិដើម Aboriginal និងអ្នកកោះ Torres Strait តាមរយៈសំឡេង។

ប្រជាជាតិផ្សេងទៀតដែលមានប្រវត្តិស្រដៀងគ្នា ដូចជាប្រទេសកាណាដា និងនូវែលសេឡង់ បានទទួលស្គាល់ ជនជាតិដើមដំបូងរបស់ពួកគេជាផ្លូវការកាលពីទសវត្សរ៍មុន។

**បទពិសោធន៍បង្ហាញថា មិនមានអ្វីដែលត្រូវភ័យខ្លាចនោះទេ - ហើយទទួលបានផលប្រយោជន៍ច្រើនណាស់។**

**Rachel Perkins, Filmmaker មកពី Alice Springs, ស្ត្រី Arrernte/Kalkadoon៖**
*"ប្រជាជនរបស់យើងបានចំណាយពេលជាច្រើនទសវត្សរ៍ ដើម្បីធ្វើយុទ្ធនាការសម្រាប់ឱកាសមួយក្នុងការកែលម្អជីវិតឱ្យកាន់តែប្រសើរ។ យើងមិនដែលបានប្ដេជ្ញាចិត្ត ឬរួបរួមគ្នាច្រើនជាងនេះទេ។ សំឡេងគឺជាកិច្ចខិតខំប្រឹងប្រែងដ៏ល្អបំផុតរបស់យើង តោះយើងនាំគ្នាចាប់ផ្ដើមធ្វើ។"*

## 5. សន្សំប្រាក់។

នៅពេលដែលរដ្ឋាភិបាលស្ដាប់ប្រជាជន ពួកគេទទួលបានលទ្ធផលកាន់តែប្រសើរ ហើយប្រើប្រាស់មូលនិធិកាន់តែមានប្រសិទ្ធភាព។

**មីង Pat Anderson AO, សហប្រធាន Uluru Dialogues, ស្ត្រី Alyawarre៖**
*"នៅពេលអ្នកទាក់ទិនជាមួយមនុស្ស អ្នកធ្វើការសម្រេចចិត្តបានកាន់តែប្រសើរ ហើយប្រាក់ដែលអ្នកចំណាយ វាទៅដល់គោលដៅដែលត្រូវការបំផុត៖ ទៅដល់សាធារណជនទូទៅ។"*

រដ្ឋាភិបាលទាំងសងខាង បានវិនិយោគរាប់ពាន់លានដុល្លារនៅក្នុងកម្មវិធីនានាដែលមិនបានដោះស្រាយបញ្ហា ឬទៅដល់សហគមន៍។

សំឡេងនឹងជួយយើងស្ដាប់អ្នកស្រុក ហើយសន្សំប្រាក់។

យើងទាំងអស់គ្នាមានជីវភាពរស់នៅកាន់តែប្រសើរ នៅពេលដែលរដ្ឋាភិបាលមិនខ្ជះខ្ជាយប្រាក់អ្នកបង់ពន្ធ ទៅលើអ្វីដែលមិនដំណើរការ។

## 6. ពេលវេលាគឺឥឡូវនេះឯង។

គំនិតនៃសំឡេងត្រូវបានរៀបចំឡើងជាច្រើនទសវត្សរ៍មកហើយ។ ជនជាតិដើម Aboriginal និងអ្នកកោះ Torres Strait ជាច្រើននាក់ បានដាក់កិច្ចខិតខំប្រឹងប្រែង និងសុច្ឆន្ទៈយ៉ាងខ្លាំងនៅក្នុងរឿងនេះ។

**ករណី Yes បន្ត** ទំព័រ 18



**តើអ្នកណាជាអ្នកសរសេររឿងនេះ?** **ខ្លឹមសារនៃហេតុផលនេះ (ដែលអាចមើលបាននៅតាមគេហទំព័រ aec.gov.au/referendums/pamphlet.htm) ត្រូវបានអនុញ្ញាតដោយសមាជិកសភាភាគច្រើនដែលបានបោះឆ្នោតគាំទ្រច្បាប់ដែលបានស្នើឡើង ហើយប្រាថ្នាចង់បន្តជំរុញករណីបែបនេះ។ អត្ថបទនេះត្រូវបានបោះពុម្ពផ្សាយដោយគ្មានការកែប្រែដោយស្នងការរៀបចំការបោះឆ្នោត។**





"សំឡេងនឹងស្ទើរតែ ក្លាយទៅជាផ្លែកបន្ទោរមួយសម្រាប់ការជជែកដេញដោលយ៉ាងយូរ អំពីបញ្ហាបច្ចុប្បន្នដ៏ច្រើនសន្ធឹកសន្ធាប់។ ស្ទើរតែគ្រប់បញ្ហានៃក្ដីបារម្ភនាពេលបច្ចុប្បន្ននៅក្នុងរបៀបវារៈជាតិ នឹងត្រូវបានមើលឃើញថាមានសមាសភាពនៃជនជាតិដើមភាគតិចមួយចំនួន។"
(*Nicholas Hasluck AM KC, អតីតចៅក្រមតុលាការកំពូល រដ្ឋអូស្ត្រាលីខាងលិច*)[5]

ហានិភ័យនៃការប្ដឹងឧទ្ធរណ៍ និងការពន្យារពេលផ្លូវច្បាប់ មានន័យថាហានិភ័យនៃរដ្ឋាភិបាលដែលដំណើរការច្របូកច្របល់។

នោះមិនល្អសម្រាប់ប្រទេសអូស្ត្រាលីទេ។

### 7. វាបើកទ្វារសម្រាប់សកម្មជន

ភាពមិនប្រាកដប្រជាផ្នែកច្បាប់ និងអវត្តមាននៃព័ត៌មានលម្អិត បង្កើតជាសំណួរថា៖ តើមានអ្វីកើតឡើងបន្ទាប់ទៀត?

> អ្នកគាំទ្រសំឡេងមួយចំនួនក្លាហានក្នុងការនិយាយថា សំឡេងនេះនឹងក្លាយជាជំហានដំបូងសម្រាប់ការសុំទោស និងសំណង ហើយនិងការផ្លាស់ប្ដូរយ៉ាងធំទូលាយផ្សេងទៀត។

"នេះជាជំហានដំបូង វាជាជំហានដ៏សំខាន់មួយ ហើយវាដាក់ការពន្យល់ទាំងអស់នៅពីក្រោយវា។ ជាឧទាហរណ៍ 'បង់ថ្លៃឈ្នួល' (ដោយព្រោះរស់នៅលើទឹកដីរបស់ជនជាតិដើមភាគតិច) តើយើងត្រូវធ្វើដូចម្ដេចក្នុងរបៀបមួយដែលមានតម្លាភាព ហើយពិតជាឃើញការសុំទោស និងសំណងដល់ជនជាតិដើម Aboriginal និងអ្នកកោះ Torres Strait…?"
(*Thomas Mayo ក្រុមការងារប្រជាមតិ*)[6]

សេចក្ដីថ្លែងការណ៍ Uluru ចេញពីបេះដូង (Uluru Statement from the Heart) និយាយថា សំឡេងគឺជាជំហានដំបូង មុនពេលនិយាយអំពីសន្ធិសញ្ញា និងការពិត។

តាមនិយមន័យ សន្ធិសញ្ញាគឺជាកិច្ចព្រមព្រៀងមួយរវាងរដ្ឋាភិបាលនានា មិនមែនរវាងពលរដ្ឋមួយក្រុម និងរដ្ឋាភិបាលរបស់ខ្លួននោះទេ។

សមាជិកនៃក្រុមការងារប្រជាមតិរបស់រដ្ឋាភិបាលបានពិពណ៌នា "ការពិត" ដូចជា "អានុភាព" ដើម្បីឈានទៅដល់ "ការលុបបំបាត់ស្ថាប័នអាណានិគមចាស់"។

"វាគឺជាមធ្យោបាយមួយដើម្បីបន្ថែមនូវអ្វីដែលយើងត្រូវការ សម្រាប់ប្រជាជនរបស់យើងនៅក្នុងការចរចាណាមួយសម្រាប់សន្ធិសញ្ញា និងសម្រាប់អ្វីៗផ្សេងទៀតដូចជាច្បាប់ កំណែទម្រង់ និងការលុបបំបាត់ស្ថាប័ន ស្ថាប័នអាណានិគមចាស់ដែលបង្កគ្រោះថ្នាក់ដល់យើង។"
(*Thomas Mayo ក្រុមការងារប្រជាមតិ*)[7]

រួចហើយនោះ សកម្មជនជាច្រើនកំពុងធ្វើយុទ្ធនាការដើម្បី**លុបចោលទិវាអូស្ត្រាលី ផ្លាស់ប្ដូរទង់ជាតិរបស់យើង និងស្ថាប័នផ្សេងទៀត ហើយនិងនិមិត្តសញ្ញា**សំខាន់ៗសម្រាប់ប្រជាជនអូស្ត្រាលី។

"វាតែងតែមានបំណងលុបចោល #abolishAustraliaDay (ទិវាអូស្ត្រាលី) ការផ្លាស់ប្ដូរកាលបរិច្ឆេទគឺជាវិធីមួយដើម្បីព្យាយាម និងចៀសវាងការធ្វើបែបនោះ។"
(*Teela Reid ក្រុមការចូលរួមប្រជាមតិ*)[8]

ប្រសិនបើសំឡេងត្រូវបានដាក់តម្កល់ក្នុងរដ្ឋធម្មនុញ្ញ ការអំពាវនាវទាំងនេះនឹងមានសំឡេងរឹតកាន់តែខ្លាំង។

"ប្រជាជនអូស្ត្រាលីត្រូវយល់ដឹងថា សំឡេងនឹងត្រូវបានគេយកប្រើដើម្បីគាំទ្រការទាមទារឱ្យមានការទទួលស្គាល់អធិបតេយ្យភាពរួម គណៈកម្មការ Makarrata ដែលត្រូវបានរចនាឡើងដើម្បីផលិតសន្ធិសញ្ញា និងសំណងរូបិយវត្ថុ និងការសរសេរឡើងវិញនូវប្រវត្តិសាស្ត្រអូស្ត្រាលី…
សក្ដានុពលនៃគ្រោះថ្នាក់ដែលមិនអាចកែប្រែបានចំពោះសង្គមអូស្ត្រាលី មានន័យថា សំឡេងមិនគួរត្រូវបានបញ្ចូលក្នុងរដ្ឋធម្មនុញ្ញអូស្ត្រាលីទេ..."
(*Terence Cole AO RFD KC អតីតចៅក្រមតុលាការកំពូល រដ្ឋញូវសៅវែល*)[9]

### 8. វានឹងមានការចំណាយយ៉ាងខ្ពស់ ហើយជាប្រព័ន្ធរដ្ឋបាលស្មុគស្មាញ

យើងមិនដឹងថាតើថវិកាបន្ថែមប៉ុន្មាននឹងត្រូវបែងចែកសម្រាប់សំឡេងនេះទេ។

នោះគឺជាព័ត៌មានលម្អិតមួយទៀតដែលនឹងត្រូវកំណត់ បន្ទាប់ពីការធ្វើប្រជាមតិ។

---

5 *ការដាក់ស្នើការសាកសួររបស់សភា* 16/4/2023
6 សុន្ទរកថា មូលនិធិ SEARCH, 12/2/2020
7 សុន្ទរកថា មូលនិធិ SEARCH, 12/2/2020
8 Twitter, 24/1/2023
9 ទស្សនាវដ្ដី Spectator Australia, 6/4/2023; ការដាក់ស្នើការសាកសួររបស់សភា 19/4/2023

**ករណី No បន្ត** ទំព័រ 19

**តើអ្នកណាជាអ្នកសរសេររឿងនេះ?** **ខ្លឹមសារនៃហេតុផលនេះ (ដែលអាចមើលបាននៅតាមគេហទំព័រ aec.gov.au/referendums/pamphlet.htm) ត្រូវបានអនុញ្ញាតដោយសមាជិកសភាភាគច្រើនដែលបានបោះឆ្នោតប្រឆាំងនឹងច្បាប់ដែលបានស្នើឡើង ហើយប្រាថ្នាចង់បន្តជំរុញករណីបែបនេះ។ អត្ថបទនេះត្រូវបានបោះពុម្ពផ្សាយដោយគ្មានការកែប្រែដោយស្នងការរៀបចំការបោះឆ្នោត។**

# ករណីសម្រាប់ការបោះឆ្នោត Yes

ការបោះឆ្នោត No មានន័យថាគ្មានអ្វីកែប្រែទេ។ វាមានន័យថាការទទួលយកពួកយើងថាមិនអាចធ្វើអ្វីបានល្អប្រសើរទេ។

**កុំប្រថុយច្រើនជាងនេះទៀត៖**

- អាយុសង្ឃឹមរស់ជាមធ្យមកាន់តែអាក្រក់។
- លទ្ធផលកាន់តែអាក្រក់នៅក្នុងវិស័យអប់រំ និងការងារ។
- លទ្ធផលកាន់តែអាក្រក់នៅក្នុងវិស័យសុខាភិបាល។

បោះឆ្នោត Yes ដើម្បីបំបាក់វដ្តនេះ ហើយបង្រួបបង្រួមជាតិយើង។

**Eddie Betts, Adelaide កីឡាករ AFL ដ៏អស្ចារ្យ អាដឺឡែត និង Carlton, Gubrun, បុរស Wirangu/Kokatha៖**

*"ខ្ញុំដឹងថាសំឡេង នឹងមិនដោះស្រាយអ្វីគ្រប់យ៉ាងពេញមួយយប់នោះទេ ប៉ុន្តែខ្ញុំមានអារម្មណ៍ថាវាជាការបើកផ្លូវមួយ ដើម្បីធ្វើឱ្យប្រាកដថា ពួកយើងត្រូវបានរួមបញ្ចូល និងគោរពនៅក្នុងការសម្រេចចិត្តលើបញ្ហានានាដែលប៉ះពាល់ដល់ពួកយើង។"*

## 7. ដំបូន្មានជាក់ស្តែងដែលមានប្រសិទ្ធភាព។

សំឡេងនឹងផ្តល់ដំបូន្មានអំពីជំហានជាក់ស្តែង ដើម្បីកែលម្អសុខភាព ការអប់រំ ការងារ និងលំនៅដ្ឋានរបស់ជនជាតិដើមភាគតិច។

ការដាក់សំឡេងក្នុងរដ្ឋធម្មនុញ្ញផ្តល់ឱ្យវានូវស្ថិរភាព និងឯករាជ្យភាពក្នុងពេលបច្ចុប្បន្ន និងទៅអនាគត។

នេះមានន័យថា សំឡេងអាចផ្តល់ដំបូន្មានដោយស្មោះត្រង់ ដោយគ្មានជាប់ពាក់ព័ន្ធក្នុងរឿងនយោបាយរយៈពេលខ្លី។

**យើងមិនអាចដោះស្រាយបញ្ហាប្រឈមទាំងអស់ដែលជនជាតិដើមភាគតិចអូស្ត្រាលីជួបប្រទះពេញមួយយប់នោះទេ។ យើងត្រូវការសកម្មភាពឥឡូវនេះ ព្រមទាំងធ្វើផែនការសម្រាប់រយៈពេលវែង។**

ហេតុនេះហើយបានជាយើងត្រូវការសំឡេង ដែលមិនអាចគូសចោលបានដោយប្រើប៊ិច។

អ្នកជំនាញផ្នែកច្បាប់បានបញ្ជាក់យ៉ាងច្បាស់ថា សំឡេងនឹងមិនមានអំណាចក្នុងការទប់ស្កាត់ ពន្យារពេល ឬជំទាស់ច្បាប់ ឬការសម្រេចចិត្តនោះទេ។ **សំឡេងគឺអំពីដំបូន្មាន**។

## 8. ការធ្វើឱ្យរដ្ឋាភិបាលបំពេញមុខការកាន់តែប្រសើរ។

ការបោះឆ្នោត Yes មានន័យថា៖

- រដ្ឋាភិបាលទទួលបានដំបូន្មានកាន់តែប្រសើរ និងផ្តល់លទ្ធផលកាន់តែប្រសើរ។
- ការបំពេញបន្ថែមលើរដ្ឋធម្មនុញ្ញដែលគាំទ្រដោយអ្នកជំនាញនានា។

មេធាវីជាន់ខ្ពស់ និងអតីតចៅក្រមតុលាការជាន់ខ្ពស់ បានចូលរួមជាផ្នែកនៃដំណើរការនេះ។

### អ្វីដែលអ្នកច្បាប់នានានិយាយ៖

- ស្របរដ្ឋធម្មនុញ្ញ និងស្របច្បាប់។
- នឹង**ពង្រឹង**ប្រព័ន្ធរដ្ឋាភិបាលរបស់យើង។
- គ្មានអំណាចជំទាស់ – សភា ហើយរដ្ឋាភិបាលបញ្ចប់ដោយចុះហត្ថលេខា។

**Robert French AC ប្រធានតុលាការជាន់ខ្ពស់នៃប្រទេសអូស្ត្រាលី ឆ្នាំ 2008-2017**
**និង Geoffrey Lindell, Emeritus សាស្ត្រាចារ្យច្បាប់ សាកលវិទ្យាល័យអាដឺឡែត៖**

*"សំឡេងគឺជាគំនិតដ៏ធំមួយ ប៉ុន្តែមិនស្មុគស្មាញទេ។ វាមានហានិភ័យទាប ហើយមានផលចំណេញយ៉ាងខ្ពស់...*
*សំឡេងនឹងផ្តល់ឱកាសជាក់ស្តែងសម្រាប់ប្រជាជនដំបូង ក្នុងការផ្តល់ ដំបូន្មានបន្ទាប់ពីបានជ្រាបព័ត៌មានសព្វគ្រប់ និងប្រកបដោយភាពស៊ីសង្វាក់គ្នា និងគួរឱ្យទុកចិត្តដល់សភា និងរដ្ឋាភិបាល។"*

- សន្លឹកមតិយោបល់រួម, ទស្សនាវដ្ដី Australian Financial Review, 4/2/2023។

## ឥឡូវនេះវាអាស្រ័យលើយើង។

**Evonne Goolagong Cawley AC MBE, អតីតកីឡាករវាយកូនបាល់លំដាប់លេខមួយពិភពលោក, ស្ត្រី Wiradjuri៖**

*"ការបោះឆ្នោត Yes គឺជាឱកាសសម្រាប់ប្រជាជនអូស្ត្រាលីទាំងអស់ ដើម្បីអបអរសាទរការរួមចំណែករបស់ជនជាតិដើម Aboriginal និងអ្នកកោះ Torres Strait ដែលបានធ្វើសម្រាប់ប្រទេសរបស់យើង និងដើម្បីជួយមនុស្សជំនាន់ក្រោយឱ្យដេញតាមក្តីសុបិនរបស់ពួកគេ។ តោះយើងនាំគ្នាចាប់យកឱកាសនេះដោយដៃទាំងពីរ។"*

ករណី Yes បន្ត ទំព័រ 20

**តើអ្នកណាជាអ្នកសរសេររឿងនេះ?**

**ខ្លឹមសារនៃហេតុផលនេះ (ដែលអាចមើលបាននៅតាមគេហទំព័រ aec.gov.au/referendums/pamphlet.htm) ត្រូវបានអនុញ្ញាតដោយសមាជិកសភាភាគច្រើនដែលបានបោះឆ្នោតគាំទ្រច្បាប់ដែលបានស្នើឡើង ហើយប្រាថ្នាចង់បន្តជំរុញករណីបែបនេះ។ អត្ថបទនេះត្រូវបានបោះពុម្ពផ្សាយដោយគ្មានការកែប្រែដោយស្ថងការរៀបចំការបោះឆ្នោត។**



# ករណីសម្រាប់ការបោះឆ្នោត No

**បច្ចុប្បន្ន មានស្ថាប័នតំណាងជនជាតិដើម Aboriginal និងអ្នកកោះ Torres Strait រាប់រយ**នៅគ្រប់ជាន់ថ្នាក់នៃរដ្ឋាភិបាល។

| |
|---|
| នៅឆ្នាំនេះ រដ្ឋាភិបាលបានបែងចែកប្រាក់ចំនួន 4.3 ពាន់លានដុល្លារ សម្រាប់ទីភ្នាក់ងារជនជាតិដើមភាគតិចអូស្ត្រាលី ដែលមានបុគ្គលិកចំនួន 1,400 នាក់។ |

គេហទំព័រ និងផែនការសាជីវកម្មរបស់ទីភ្នាក់ងារនេះនិយាយថា៖ "យើង... ធានាថាជនជាតិដើម Aboriginal និងអ្នកកោះ Torres Strait មានមតិយោបល់នៅក្នុងការសម្រេចចិត្តនានាដែលប៉ះពាល់ដល់ពួកគេ។"

មិនមានការណែនាំដែលថាសំឡេងនេះនឹងជំនួសទីភ្នាក់ងារណាមួយក្នុងចំណោមទីភ្នាក់ងារទាំងនេះទេ។ វានឹងដំណើរការជាប្រព័ន្ធរដ្ឋបាលស្មុគស្មាញមួយក្នុងចំណោម ទីភ្នាក់ងារជាច្រើន។

## 9. សំឡេងនេះនឹងមានលក្ខណៈអចិន្ត្រៃយ៍

សំឡេងនេះមិនមែនជាកម្មវិធីសាកល្បង ឬសាកមើលនោះទេ។ វានឹងមិនមានចែងនៅក្នុងច្បាប់ដែលអាចប្តូរបញ្ច្រាសទៅវិញឡើយ។

នៅពេលដែលវានៅក្នុងរដ្ឋធម្មនុញ្ញហើយនោះ គេមិនអាចលុបចោលវាបានទេ។

នៅពេលដែលតុលាការជាន់ខ្ពស់ធ្វើការបកស្រាយហើយនោះ សភាមិនអាចបដិសេធចោលវាបានទេ។

យើងនឹងជាប់គាំងជាមួយនឹងផលវិបាកអវិជ្ជមាននានាជារៀងរហូត។

## 10. មានវិធីដែលប្រសើរជាងទៅថ្ងៃមុខ

ការធ្វើប្រជាមតិនេះមិនមែនគ្រាន់តែនិយាយអំពី ទទួលស្គាល់ជនជាតិដើមភាគតិចអូស្ត្រាលីក្នុងរដ្ឋធម្មនុញ្ញនោះទេ។

**ការនេះអាចសម្រេចបានដោយមិនចាំបាច់ភ្ជាប់វាទៅនឹងសំឡេងដែលប្រថុយប្រថាន គ្មានអ្នកណាដឹង និងលក្ខណៈអចិន្ត្រៃយ៍។**

ការទទួលស្គាល់មានការគាំទ្រយ៉ាងទូលំទូលាយពីប្រជាជនអូស្ត្រាលី។ ទោះជាយ៉ាងណាក្តី សំណើសំឡេងនេះគឺបង្កជាបញ្ហា។

មានប្រជាជនអូស្ត្រាលីជាច្រើននាក់ដែលប្រឆាំងនឹងសំឡេង ផ្អែកលើគោលសីលធម៌។

អ្នកផ្សេងទៀតប្រហែលជាមានឆន្ទៈពិចារណាជម្រើសសំឡេង ដែលមិនសូវប្រថុយប្រថាន ប៉ុន្តែរដ្ឋាភិបាលមិនបានផ្តល់ឱ្យអ្នកនូវជម្រើសនេះទេ។

នៅពេលដែលការផ្លាស់ប្តូរពីមុនចំពោះរដ្ឋធម្មនុញ្ញត្រូវបានស្នើឡើង មានអនុសញ្ញារដ្ឋធម្មនុញ្ញ ដើម្បីពិចារណាឱ្យបានត្រឹមត្រូវនូវជម្រើស និងព័ត៌មានលម្អិតនានា។

មិនមានដំណើរការបែបនេះកើតឡើងនៅទីនេះទេ។ ដំណើរការនេះត្រូវបានធ្វើឡើងដោយប្រញាប់ប្រញាល់ និងតឹងរ៉ឹង។

វិធីសាស្ត្រនេះមិនមែនជាការបង្រួបបង្រួម ឬមានប្រសិទ្ធភាពទេ។ វាគឺជាការបំបែកបំបាក់។

## ការសម្រេចចិត្តនេះគឺជារបស់អ្នក

នេះគឺជាការសម្រេចចិត្តដ៏សំខាន់បំផុតមួយ។ ជាអកុសល សំណួរ និងកង្វល់ស្របច្បាប់នានារបស់ប្រជាជនអូស្ត្រាលីជាច្រើនត្រូវបានគេរុញច្រានចោល។

ជាសំណាងល្អ ប្រជាមតិនេះនឹងមិនត្រូវបានសម្រេចដោយអ្នកនយោបាយ សាជីវកម្ម ឬតារាល្បីៗនោះទេ។

វានឹងត្រូវបានសម្រេចដោយប្រជាជនអូស្ត្រាលីគ្រប់រូប។ វាប៉ះពាល់ដល់ប្រជាជនអូស្ត្រាលីគ្រប់រូប។

**ប្រសិនបើអ្នកមិនដឹងទេ  សូមបោះឆ្នោត no។**

## ព័ត៌មានបន្ថែម

សម្រាប់ព័ត៌មាន និងព័ត៌មានទាន់បច្ចុប្បន្នភាព សូមចូលទៅកាន់គេហទំព័រ៖

- www.riskyvoice.com
- www.oneandfree.au
- www.australiansforunity.com.au

ចុងបញ្ចប់នៃករណី **NO**។

**តើអ្នកណាជាអ្នកសរសេររឿងនេះ?**

**ខ្លឹមសារនៃហេតុផលនេះ (ដែលអាចមើលបាននៅតាមគេហទំព័រ aec.gov.au/referendums/pamphlet.htm) ត្រូវបានអនុញ្ញាតដោយសមាជិកសភាភាគច្រើនដែលបានបោះឆ្នោតប្រឆាំងនឹងច្បាប់ដែលបានស្នើឡើង ហើយប្រាថ្នាចង់បន្តជំរុញករណីបែបនេះ។ អត្ថបទនេះត្រូវបានបោះពុម្ពផ្សាយដោយគ្មានការកែប្រែដោយស្ថងការរៀបចំការបោះឆ្នោត។**

# ករណីសម្រាប់ការបោះឆ្នោត Yes

ជនជាតិដើម Aboriginal និងអ្នកកោះ Torres Strait បានផ្តល់ឱ្យយើងនូវឱកាសម្តងក្នុងមួយជំនាន់។

**យើងអាចបោះឆ្នោត Yes ដើម្បីជាផ្នែកនៃពេលវេលាបង្រួបបង្រួមដ៏អស្ចារ្យមួយ ដែលនឹងនាំមកនូវអនាគតកាន់តែប្រសើរមួយ។**

យើងអាចបោះឆ្នោត Yes ដើម្បី៖

- ផ្តល់ភាពយុត្តិធម៌ដល់ជនជាតិដើម Aboriginal និងអ្នកកោះ Torres Strait។
- ផ្តល់ឱកាសដល់មនុស្សដើម្បីបញ្ចេញមតិ អំពីបញ្ហានានាដែលប៉ះពាល់ដល់ពួកគេ។
- បង្កើតភាពខុសគ្នាជាក់ស្តែងដែលធ្វើឱ្យជីវិតប្រសើរឡើង។

តោះយើងនាំគ្នាបោះឆ្នោត Yes សម្រាប់**ការទទួលស្គាល់ ការស្តាប់** និង**លទ្ធផលកាន់តែប្រសើរ**។

តោះយើងនាំគ្នាបោះឆ្នោត Yes ដើម្បីធានាថាជនជាតិដើម Aboriginal និងអ្នកកោះ Torres Strait មានជីវិតរស់នៅកាន់តែប្រសើរ ជាមួយនឹងឱកាសកាន់តែច្រើនសម្រាប់កូនៗរបស់ពួកគេ។

ក្នុងស្មារតីរួបរួមគ្នា តោះយើងនាំគ្នាបោះឆ្នោត Yes ទាំងអស់គ្នា។

**ចុងបញ្ចប់នៃករណី YES។**

**តើអ្នកណាជាអ្នកសរសេររឿងនេះ?**

**ខ្លឹមសារនៃហេតុផលនេះ (ដែលអាចមើលបាននៅតាមគេហទំព័រ aec.gov.au/referendums/pamphlet.htm) ត្រូវបានអនុញ្ញាតដោយសមាជិកសភាភាគច្រើនដែលបានបោះឆ្នោតគាំទ្រច្បាប់ដែលបានស្នើឡើង ហើយប្រាថ្នាចង់បន្តជំរុញករណីបែបនេះ។ អត្ថបទនេះត្រូវបានបោះពុម្ពផ្សាយដោយគ្មានការកែប្រែដោយស្នងការរៀបចំការបោះឆ្នោត។**



# ករណីសម្រាប់ការបោះឆ្នោត No

ករណី No បញ្ចប់នៅទំព័រ 19

**តើអ្នកណាជាអ្នកសរសេររឿងនេះ?**

**ខ្លឹមសារនៃហេតុផលនេះ (ដែលអាចមើលបាននៅតាមគេហទំព័រ aec.gov.au/referendums/pamphlet.htm) ត្រូវបានអនុញ្ញាតដោយសមាជិកសភាភាគច្រើនដែលបានបោះឆ្នោតប្រឆាំងនឹងច្បាប់ដែលបានស្នើឡើង ហើយប្រាថ្នាចង់បន្តជំរុញករណីបែបនេះ។ អត្ថបទនេះត្រូវបានបោះពុម្ពផ្សាយដោយគ្មានការកែប្រែដោយស្នងការរៀបចំការបោះឆ្នោត។**

ទំព័រនេះត្រូវបានទុកឱ្យនៅទទេដោយចេតនា



AEC
Australian Electoral Commission

# សៀវភៅមគ្គុទ្ទេសក៍ផ្លូវការរបស់អ្នក

## ទៅកាន់ការធ្វើប្រជាមតិ ឆ្នាំ2023

**តើថ្ងៃបោះឆ្នោតធ្វើនៅពេលណា?**

សម្រាប់ព័ត៌មានបន្ថែម សូមស្កេនកូដ QR ឬចូលមើលគេហទំព័រ
aec.gov.au/referendums

**aec.gov.au**
13 23 26

ផ្តល់សិទ្ធិអនុញ្ញាតដោយស្នងការរៀបចំការបោះឆ្នោត 10 Mort Street ទីក្រុង Canberra
Authorised by the Electoral Commissioner, 10 Mort Street, Canberra

# **សារចេញពី**ស្នងការរៀបចំការបោះឆ្នោត

វាមានរយៈពេលយូរបន្តិចហើយចាប់តាំងពីយើងបានធ្វើប្រជាមតិមួយ។ ប្រជាមតិលើកចុងក្រោយត្រូវបានធ្វើឡើងក្នុងឆ្នាំ 1999 ដែលមានន័យថា សម្រាប់មនុស្សជាច្រើនដែលកំពុងអានអត្ថបទនេះ វានឹងជាលើកដំបូងដែលពួកគេបានបោះឆ្នោតនៅក្នុងប្រជាមតិ។

ការធ្វើប្រជាមតិគឺជាការបោះឆ្នោតជាតិ លើសំណួរមួយអំពីការកែប្រែដែលបានស្នើឡើងចំពោះរដ្ឋធម្មនុញ្ញ – ក្នុងករណីនេះ ថាតើត្រូវកែប្រែរដ្ឋធម្មនុញ្ញក្នុងការទទួលស្គាល់ ជនជាតិដើមដំបូងរបស់អូស្ត្រាលី ដោយការបង្កើតសំឡេងជនជាតិដើម Aboriginal និងអ្នកកោះ Torres Strait ឬអត់។

ការបោះឆ្នោតប្រជាមតិគឺខុសពីការបោះឆ្នោតជ្រើសតាំង ហើយលទ្ធផលគឺផ្អែកលើរបៀបដែល 'សំឡេងភាគច្រើនពីរកម្រិត' – បោះឆ្នោត – ពោលគឺ៖

- ភាគច្រើនទូទាំងប្រទេស (ច្រើនជាង 50%) ពីគ្រប់រដ្ឋ និងដែនដីទាំងអស់ និង
- ភាគច្រើន (ច្រើនជាង 50%) ធ្វើឡើងភាគច្រើននៃរដ្ឋផ្សេងៗ (យ៉ាងហោចណាស់បួនរដ្ឋក្នុងចំណោមរដ្ឋទាំងប្រាំមួយ)។

AEC បានបង្កើតសៀវភៅមគ្គុទ្ទេសក៍នេះ ដើម្បីជួយអ្នកធ្វើផែនការសម្រាប់ការបោះឆ្នោតប្រជាមតិរបស់អ្នក រួមទាំងរបៀបបោះឆ្នោតឱ្យបានត្រឹមត្រូវ អ្វីដែលនឹងកើតឡើងនៅកន្លែងបោះឆ្នោត និងគន្លឹះនានាអំពីរបៀបពិនិត្យមើលប្រភពព័ត៌មាន។

យើងនឹងមានកន្លែងបោះឆ្នោតជាង 7,000 កន្លែងបើកដំណើរការនៅទូទាំងប្រទេសនៅថ្ងៃបោះឆ្នោត ជម្រើសបោះឆ្នោតមុនពេលកំណត់ និងក្រុមសេវាកម្មអ្នកបោះឆ្នោតនៅទីដាច់ស្រយាលច្រើនជាងពេលមុនៗដែលអញ្ជើញទៅកាន់ទីកន្លែងដាច់ស្រយាលនានា។

ភាពមិនលំអៀង និងឯករាជ្យ គឺជាមូលដ្ឋានគ្រឹះរបស់គណៈកម្មការរៀបចំការបោះឆ្នោតអូស្ត្រាលី។ តម្លាភាព សុវត្ថិភាព និងគណនេយ្យភាពនៅក្នុងដំណើរការនានាដែលយើងធ្វើ មានសារៈសំខាន់ និងអាចមើលឃើញយ៉ាងច្បាស់។

ខ្ញុំមានមោទនភាពចំពោះតួនាទីដែលយើងបំពេញក្នុងការប្រគល់ជូនការធ្វើប្រជាមតិប្រកបដោយសុចរិតភាពនៅគ្រប់ជំហាននៃដំណើរការ។

សូមចូលមើលគេហទំព័រ **aec.gov.au/referendums** សម្រាប់ព័ត៌មានបន្ថែម។

**Tom Rogers**
ស្នងការរៀបចំការបោះឆ្នោត

អ្នកមានសិទ្ធិបោះឆ្នោតច្រើនជាង
97%
នៅក្នុងបញ្ជីបោះឆ្នោត

7,000+
កន្លែងបោះឆ្នោត

500+
មណ្ឌលបោះឆ្នោតមុនពេលកំណត់

រហូត
100,000
បុគ្គលិកបណ្ដោះអាសន្នជំនួយការធ្វើប្រជាមតិ

# **ឈប់ ហើយពិចារណា**

## ពិនិត្យមើលប្រភពនៅក្នុងការធ្វើប្រជាមតិនេះ

ក្នុងអំឡុងពេលធ្វើប្រជាមតិ អ្នកអាចប្រទះឃើញព័ត៌មានអំពីដំណើរការបោះឆ្នោតដែលគ្មានភស្តុតាងគាំទ្រ បាត់បរិបទ ឬមានការបំភាន់។

AEC គឺជាទីភ្នាក់ងារឯករាជ្យ ដែលត្រូវបានផ្តល់ភារកិច្ចឱ្យគ្រប់គ្រងការធ្វើប្រជាមតិ។ យើងនឹងទំនាក់ទំនងជាមួយអ្នកបោះឆ្នោត អំពីលក្ខខណ្ឌតម្រូវរបស់ពួកគេក្នុងការចូលរួម គោលបំណងនៃការធ្វើប្រជាមតិ និងជម្រើសបោះឆ្នោតនានា។

វាសំខាន់ណាស់ដែលអ្នកត្រូវពិចារណាដោយប្រុងប្រយ័ត្ននូវអ្វីដែលអ្នកឃើញ ស្តាប់ឮ និងអានអំពីដំណើរការធ្វើប្រជាមតិ។

សូមចំណាយពេលដើម្បីពិចារណាថាតើព័ត៌មាននោះ៖

- មកពីប្រភពដែលអាចទុកចិត្តបាន ឬដែលអាចទទួលស្គាល់បាន
- បច្ចុប្បន្ន
- មានសុវត្ថិភាព (មិនមែនជាការបោកប្រាស់)។

នេះមានសារៈសំខាន់ជាពិសេសពេលណានៅលើប្រព័ន្ធផ្សព្វផ្សាយសង្គម និងអនឡាញ។

សូមចូលទៅកាន់ **aec.gov.au/stopandconsider** សម្រាប់ព័ត៌មានបន្ថែម និងវីដេអូខ្លីៗដែលមានគន្លឹះដ៏មានប្រយោជន៍។




ផ្តល់សិទ្ធិអនុញ្ញាតដោយស្នងការរៀបចំការបោះឆ្នោត 10 Mort Street ទីក្រុង Canberra

# **ធ្វើផែនការជាមុនដើម្បីបោះឆ្នោតប្រជាមតិ**

## កន្លែងបោះឆ្នោតនឹងបើកនៅម៉ោង 8 ព្រឹក ហើយបិទនៅម៉ោង 6 ល្ងាចជាកំណត់

### តើអ្នកណាត្រូវតែបោះឆ្នោត?

ប្រជាពលរដ្ឋអូស្ត្រាលីទាំងអស់ដែលមានអាយុចាប់ពី 18 ឆ្នាំឡើងទៅ ត្រូវបានតម្រូវឱ្យចុះឈ្មោះ និងបោះឆ្នោតនៅក្នុងការធ្វើប្រជាមតិនេះ។

### តើខ្ញុំអាចបោះឆ្នោតនៅឯណា?

អ្នកអាចបោះឆ្នោតនៅកន្លែងបោះឆ្នោតណាមួយក្នុងរដ្ឋ ឬដែនដីរបស់អ្នកនៅថ្ងៃបោះឆ្នោត។ កន្លែងបោះឆ្នោតបើកពីម៉ោង 8 ព្រឹក ដល់ម៉ោង 6 ល្ងាច។

កន្លែងបោះឆ្នោតជាធម្មតាមានទីតាំងនៅសាលារៀនក្នុងតំបន់ ព្រះវិហារ សាលសហគមន៍ និងអគារសាធារណៈ។ ដើម្បីស្វែងរកកន្លែងបោះឆ្នោតដែលនៅជិតអ្នកបំផុត សូមចូលមើលគេហទំព័រ **aec.gov.au/where**

ប្រសិនបើអ្នកមានការលំបាកផ្នែកចល័តភាព ឬពិការភាព ឬថែទាំនរណាម្នាក់ដែលមានពិការភាព អ្នកអាចពិនិត្យមើលព័ត៌មានលម្អិតអំពីច្រកផ្លូវចេញចូលនៃកន្លែងបោះឆ្នោតនៅតាមគេហទំព័រ **aec.gov.au/where**

សម្រាប់ជម្រើសបោះឆ្នោតអ្នកពិការភ្នែក ឬមានចក្ខុវិស័យទាប សូមចូលមើលគេហទំព័រ **aec.gov.au/assistance** ឬហៅទូរសព្ទលេខ **13 23 26**។

### ចុះប្រសិនបើខ្ញុំស្ថិតនៅក្នុងរដ្ឋ ឬដែនដីផ្សេងទៀត?

ប្រសិនបើអ្នកនឹងស្ថិតនៅអន្តររដ្ឋនៅថ្ងៃបោះឆ្នោត អ្នកអាចបោះឆ្នោតបាននៅតាមមណ្ឌលបោះឆ្នោតអន្តររដ្ឋដែលបានកំណត់ ឬពិចារណាលើជម្រើសបោះឆ្នោតមុនពេលកំណត់នានា។

### ចុះប្រសិនបើខ្ញុំមិនអាចទៅកន្លែងបោះឆ្នោតនៅថ្ងៃបោះឆ្នោតបានទេ?

ប្រសិនបើអ្នកមិនអាចទៅកន្លែងបោះឆ្នោតក្នុងរដ្ឋ ឬដែនដីរបស់អ្នកនៅថ្ងៃបោះឆ្នោតបានទេ អ្នកប្រហែលជាអាចមានសិទ្ធិបោះឆ្នោតមុនពេលកំណត់ដោយផ្ទាល់ ឬតាមប្រៃសណីយ៍។

### របៀបបោះឆ្នោតមុនពេលកំណត់ដោយផ្ទាល់

ប្រសិនបើអ្នកមានសិទ្ធិ អ្នកអាចបោះឆ្នោតមុនថ្ងៃបោះឆ្នោត។ មណ្ឌលបោះឆ្នោតមុនពេលកំណត់បើកពីថ្ងៃចន្ទ ពីរសប្តាហ៍មុនថ្ងៃបោះឆ្នោត។ កាលបរិច្ឆេទ និងម៉ោងបើកដំណើរការគឺខុសៗគ្នា ដូច្នេះសូមចូលមើលគេហទំព័រ **aec.gov.au/where** ដើម្បីពិនិត្យមើលព័ត៌មានលម្អិតសម្រាប់មណ្ឌលបោះឆ្នោតនីមួយៗ។

សម្រាប់ព័ត៌មានបន្ថែមអំពីការបោះឆ្នោតមុនពេលកំណត់ និងដើម្បីពិនិត្យមើលថាតើអ្នកមានសិទ្ធិដែរឬទេ សូមចូលទៅកាន់គេហទំព័រ **aec.gov.au/early** ឬហៅទូរសព្ទលេខ **13 23 26**។

### របៀបបោះឆ្នោតមុនពេលកំណត់តាមប្រៃសណីយ៍

ការបោះឆ្នោតតាមប្រៃសណីយ៍មានសម្រាប់អ្នកបោះឆ្នោតដែលមានសិទ្ធិ។ ពិនិត្យមើលភាពមានសិទ្ធិរបស់អ្នក ហើយដាក់ពាក្យតាមអនឡាញនៅតាមគេហទំព័រ **aec.gov.au/pva** ឬដោយការស្កេនកូដ QR ។

សូមហៅទូរសព្ទលេខ **13 23 26** ប្រសិនបើអ្នកមិនមានលទ្ធភាពចូលដំណើរការតាមអនឡាញ ហើយចង់ដាក់ពាក្យបោះឆ្នោតតាមប្រៃសណីយ៍។

បំពេញពាក្យសុំបោះឆ្នោតតាមប្រៃសណីយ៍របស់អ្នក ដើម្បីផ្ញើវាឱ្យបានដល់ AEC **មិនលើសពីម៉ោង6ល្ងាច នៅថ្ងៃពុធមុនថ្ងៃបោះឆ្នោត។**

# **តើមានអ្វីកើតឡើងនៅកន្លែងបោះឆ្នោត**

1. នៅពេលអ្នកទៅដល់ចំណុចចេញសន្លឹកឆ្នោត មន្ត្រីជំនួយការបោះឆ្នោតនឹងសួរឈ្មោះពេញ និងអាសយដ្ឋានរបស់អ្នក ហើយថាតើអ្នកបានបោះឆ្នោតហើយឬនៅនៅក្នុងការបោះឆ្នោតប្រជាមតិឆ្នាំ 2023។ ឈ្មោះរបស់អ្នកនឹងត្រូវបានគេគូសចេញពីបញ្ជីបោះឆ្នោត។
2. អ្នកនឹងទទួលបានសន្លឹកឆ្នោតរបស់អ្នក។
3. សូមអានការណែនាំនៅលើសន្លឹកឆ្នោតដោយប្រុងប្រយ័ត្ន។
4. បំពេញសន្លឹកឆ្នោតរបស់អ្នក។
5. នៅពេលអ្នកបានបំពេញសន្លឹកឆ្នោតរបស់អ្នករួចហើយ សូមបត់វា ហើយដាក់វានៅក្នុងប្រអប់សន្លឹកឆ្នោតដែលបានផ្តល់។
6. ប្រសិនបើអ្នកបានប្រើខ្មៅដៃរបស់ AEC សូមដាក់វានៅក្នុងប្រអប់នៅពេលចាកចេញ។ នឹងមានទឹកថ្នាំអនាម័យសម្អាតដៃនៅក្បែរច្រកចេញ។

**សូមចងចាំ ប្រសិនបើអ្នកត្រូវការជំនួយ អ្នកអាចនាំនរណាម្នាក់ដែលអ្នកទុកចិត្តមកជាមួយអ្នក ឬសួរមន្ត្រីជំនួយការបោះឆ្នោតម្នាក់។**

**AEC យកចិត្តទុកដាក់ចំពោះសុវត្ថិភាពរបស់អ្នកបោះឆ្នោត និងបុគ្គលិករបស់យើងយ៉ាងខ្លាំង។ AEC បន្តត្រួតពិនិត្យបរិស្ថាន COVID-19 និងធ្វើតាមដំបូន្មានពីអាជ្ញាធរសុខាភិបាលពាក់ព័ន្ធនានា។ ព័ត៌មាននៅក្នុងសៀវភៅមគ្គុទ្ទេសក៍នេះ ឆ្លុះបញ្ចាំងពីកាលៈទេសៈនានានៅពេលបោះពុម្ពផ្សាយ។ នេះអាចបណ្តាលឱ្យមានការផ្លាស់ប្តូរវិធានការនានាដែលបានដាក់ដំណើរការ។**

**ទឹកថ្នាំអនាម័យសម្អាតដៃនឹងអាចរកបាន ហើយអ្នកត្រូវបានលើកទឹកចិត្តឱ្យយកម៉ាស់មុខមកជាមួយ ហើយពាក់ និងរក្សាគម្លាតរាងកាយ។ អ្នកអាចប្រើខ្មៅដៃរបស់ AEC ស្អាតមួយ ឬអ្នកអាចយកខ្មៅដៃ ឬប៊ិចផ្ទាល់ខ្លួនរបស់អ្នកមកជាមួយក៏បានដែរ។**

Authorised by the Electoral Commissioner, 10 Mort Street, Canberra

# របៀបឱ្យសន្លឹកឆ្នោតរបស់អ្នកយកជាផ្លូវការបាន

ចំពោះការធ្វើប្រជាមតិនេះ អ្នកនឹងទទួលនូវសន្លឹកឆ្នោតមួយសន្លឹក
ជាមួយនឹងការកែប្រែដែលបានស្នើឡើងចំពោះរដ្ឋធម្មនុញ្ញអូស្ត្រាលី។

នៅលើសន្លឹកឆ្នោត៖

សូមសរសេរ **YES** ប្រសិនបើអ្នកយល់ព្រម លើការកែប្រែដែលបានស្នើឡើង



Commonwealth of Australia

**BALLOT PAPER**

State/territory

**Referendum on proposed Constitution alteration**

**DIRECTIONS TO VOTER**

**Write "YES" or "NO" in the space provided opposite the question set out below.**

**A PROPOSED LAW:**
There would be a description of the proposed constitutional change here.

**DO YOU APPROVE THIS PROPOSED ALTERATION?** YES

WRITE "YES" OR "NO"



សន្លឹកឆ្នោតគំរូ

ឬ

សូមសរសេរ **NO** ប្រសិនបើអ្នកមិនយល់ព្រម លើការកែប្រែដែលបានស្នើឡើង



Commonwealth of Australia

**BALLOT PAPER**

State/territory

**Referendum on proposed Constitution alteration**

**DIRECTIONS TO VOTER**

**Write "YES" or "NO" in the space provided opposite the question set out below.**

**A PROPOSED LAW:**
There would be a description of the proposed constitutional change here.

**DO YOU APPROVE THIS PROPOSED ALTERATION?** NO

WRITE "YES" OR "NO"



សន្លឹកឆ្នោតគំរូ

អ្នកគួរតែសរសេរចម្លើយរបស់អ្នកជាភាសាអង់គ្លេស។

សូមកុំបារម្ភប្រសិនបើអ្នកបំពេញខុស។
អ្នកអាចស្នើសុំសន្លឹកឆ្នោតមួយផ្សេងទៀត ហើយចាប់ផ្តើមបំពេញម្តងទៀត។

**ការបោះឆ្នោតគឺជាកាតព្វកិច្ចសម្រាប់ពលរដ្ឋអូស្ត្រាលីដែលមានអាយុចាប់ពី 18 ឆ្នាំឡើងទៅ។
ប្រសិនបើអ្នកមិនបោះឆ្នោតទេ អ្នកអាចនឹងត្រូវពិន័យ ឬត្រូវបានកាត់ទោស។
ប្រសិនបើអ្នកបោះឆ្នោតច្រើនជាងម្តង នេះគឺជាបទល្មើសព្រហ្មទណ្ឌ។**

ផ្តល់សិទ្ធិអនុញ្ញាតដោយស្នងការរៀបចំការបោះឆ្នោត 10 Mort Street ទីក្រុង Canberra | Authorised by the Electoral Commissioner, 10 Mort Street, Canberra